**BMI0192**

**សម្ភាសន៍ជាមួយឈ្មោះ ឈុំ សេង ភេទប្រុស អាយុ៥៧ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ប្រធានកងធំលើកទំនប់អាងត្រពាំងថ្ម**

**រស់នៅភូមិតាវង់ ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ**

**សម្ភាសន៍ថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា**

**០១:៤៦:១០**

**៥៥ទំព័រ**

ដារ៉ាៈ អញ្ចឹងពូ ដំបូងពួកខ្ញុំចង់ណែនាំខ្លួនពួកខ្ញុំឲ្យពូបានស្គាល់សិនណា៎ ខ្ញុំឈ្មោះ ដារ៉ា មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនេះឈ្មោះ ប្រុញ ឈ្មោះ ដាតា ហើយនឹងឈ្មោះប៊ុនថន សុទ្ធតែជាអ្នកធ្វើនៅការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយយើងមកថ្ងៃនេះគឺមកចង់ជួបពូ ចង់សួរនាំពូអំពីការងារនៅត្រពាំងថ្មកាលពីជំនាន់ ប៉ុល ពត ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាយើង គឺជាអង្គការក្រៅរដ្ឋាភិបាលដែលមិនពាក់ព័ន្ធរឿងនយោបាយ ហើយជាអង្គការសិក្សាស្រាវជ្រាវនឹងចងក្រងឯកសារពីសម័យខ្មែរក្រហម ទុកឲ្យកូនចៅជំនាន់ក្រោយទៀត សិក្សារៀនសូត្របន្តទៀតអញ្ចឹងណា៎ ស្វែងយល់តទៅទៀតដើម្បីទុកជាការទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍វិលត្រលប់មកស្រុកខ្មែរម្តងទៀត អញ្ចឹងបន្ទាប់ពីបានណែនាំខ្លួនអញ្ចឹង ខ្ញុំចាប់ផ្តើមសុំការអនុញ្ញាតិសម្ភាសន៍ពូ ពូអនុញ្ញាតិឲ្យខ្ញុំសម្ភាសន៍ហើយណាស់?

សេងៈ បាទ! មិនអីទេ។

ដារ៉ាៈ អត់មានយល់ទាស់អីទេ?

សេងៈ អត់មានយល់ទាស់អីទេ។

ដារ៉ាៈ អញ្ចឹងថ្ងៃនេះថ្ងៃ១៨ ខែមិថុនា ឆ្នាំ២០១១ ហើយវេលាម៉ោង១០:៤០នាទី ដែលខ្ញុំសម្ភាសន៍ពូណា៎ពូ អញ្ចឹងមុនដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូពេញហ្នឹង តើពូឈ្មោះអីដែរ?

សេងៈ ខ្ញុំបាទឈ្មោះ ឈុំ សេង។

ដារ៉ាៈ ឈុំ?

សេងៈ បាទ! អាយុ៥៧ឆ្នាំ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

ដារ៉ាៈ មានស្រុកកំណើតនៅណាដែរ?

សេង៖ ស្រុកកំណើតនៅភូមិភ្នំលៀប ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។

ដារ៉ាៈ កាលហ្នឹងព្រះនេត្រព្រះហ្នឹងនៅបាត់ដំបងទេពូណ៎!?

សេង៖ បាទ! ខេត្តបាត់ដំបង ។

ដារ៉ាៈ ចុះឥឡូវមកស្អីវិញ?

សេង៖ បន្ទាយមានជ័យ ។

ដារ៉ាៈ អញ្ចឹងសព្វថ្ងៃពូរស់នៅ?

សេង៖ ខ្ញុំរស់នៅភូមិតាវេង ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

ដារ៉ាៈ ពូមានឈ្មោះ ឈុំ សេង ពីមុនមករហូតឬក៏មានការដូរឈ្មោះដែរ?

សេង៖ ខ្ញុំមានឈ្មោះតែមួយគត់ តែដល់ក្រោយមកគេចេះតែហៅលេងធម្មតា ហៅក្រៅផ្លូវការថា តាសេងស្រាគីឡូ ព្រោះខ្ញុំធ្លាប់ផឹកស្រាសគេចេះតែហៅលេងៗទៅ តែឈ្មោះផ្លូវការគឺ ឈ្មោះ ឈុំ សេងៗអញ្ចឹងឯង ។

ដារ៉ាៈ ហើយទោះបីជាឈ្មោះពូនៅសម័យប៉ុល ពត ហ្នឹងក៏ពូដាក់ឈ្មោះ សេង អញ្ចឹងដែរ?

សេង៖ បាទ! សេង អញ្ចឹងដែរ សេង រហូត ។

ដារ៉ាៈ ពូមានគ្រួសារឈ្មោះអីពូ?

សេង៖ គ្រួសារខ្ញុំឈ្មោះ វឿ ធូ ។

ដារ៉ាៈ គាត់អាយុប៉ុន្មានឆ្នាំហើយ?

សេង៖ អាយុ៥៦ឆ្នាំ ។

ដារ៉ាៈ គាត់អ្នកស្រុកកំណើតហ្នឹងដែរ?

សេង៖ បាទ! ស្រុកកំណើតនៅភូមិតាវេង ឃុំពន្លៃ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ។

ដារ៉ាៈ ហើយពូមានកូនចៅប៉ុន្មាននាក់ដែរ?

សេង៖ ខ្ញុំមានកូន៣នាក់ ។

ដារ៉ាៈ ៣នាក់?

សេង៖ បាទ!

ដារ៉ាៈ ហើយកូនធំៗអស់ហើយ?

សេង៖ ធំៗអស់ហើយ មួយនៅរៀន គ្រូនៅគរុកោសល្យខេត្តបាត់ដំបង ។

ដារ៉ាៈ ហើយ២នាក់ទៀត?

សេង៖	២នាក់ទៀតគេនៅផ្ទះ បានគ្រួសារមួយនៅមួយ ។

ដារ៉ា៖	នៅមួយហ្នឹងនៅរៀននៅសូត្រដែរ?

សេង៖	អត់ទេ គេឈប់ហើយ គេទៅជួយស្ទូង ។

ដារ៉ា៖	ឪពុកម្ដាយពូឈ្មោះអីដែរ?

សេង៖	ឪពុកខ្ញុំឈ្មោះ នូ គិន ។

ដារ៉ា៖	នូ គិន?

សេង៖	បាទ! គាត់ស្លាប់កាលសម័យ៣ឆ្នាំ ។

ដារ៉ា៖	ស្លាប់កាលសម័យប៉ុល ពត ហ្នឹងមែន?

សេង៖	បាទ! សម័យប៉ុល ពត ។

ដារ៉ា៖	ស្លាប់ដោយសារមូលហេតុអីដែរ?

សេង៖	គេបង្អត់អាហារ ។

ដារ៉ា៖	អញ្ចឹង?

សេង៖	បាទ! គេបង្អត់អាហារ បង្អត់ទឹក គេឲ្យហូបបបរបន្តិចៗ ដល់ហើយគាត់ហើម ហើយស្លាប់ទៅ ។

ដារ៉ា៖	អញ្ចឹងពេលដែលគាត់ស្លាប់ហ្នឹងពូនៅក្នុងភូមិជាមួយគាត់ដែរ ឬក៏ម៉េច?

សេង៖	អត់ទេ ពេលហ្នឹងគេត្រូវសម្លាប់ខ្ញុំដែរ ព្រោះប្រវត្តិខ្ញុំជាទាហានលន់ នល់ ។

ដារ៉ា៖	អញ្ចឹងពីមុនពូមានបម្រើទាហានលន់ នល់?

សេង៖	បាទ! ដល់ពេលធ្វើជាទាហានលន់ នល់ ទៅ គេចូលមកគេស្រាវជ្រាវរកទាហានអាយ័ន គេប្រុងសម្លាប់ ហើយខ្ញុំក៏គេចចេញពីភូមិទៅនៅចល័ត ហើយចល័តមុនដំបូងគឺកំបោរស្រែះ ហើយបានដកពីកំបោរស្រែះមក ។

ដារ៉ា៖	ត្រឹមហ្នឹងសិន អញ្ចឹងឪពុកលោកពូស្លាប់ដោយសារអត់អាហារ ជម្ងឺហើម?

សេង៖	បាទ!

ដារ៉ា៖	ហើយពេលដែលស្លាប់ហ្នឹងពូនៅហ្នឹងដែរឬក៏អត់ទេ?

សេង៖	អត់ទេ ខ្ញុំនៅចល័ត ។

ដារ៉ា៖	ចុះម្ដាយរបស់ពូ?

សេង៖	ម្ដាយទើបតែស្លាប់ទេ ជារោគារបស់គាត់ គាត់ទើបតែស្លាប់កាលឆ្នាំប៉ុន្មានទេ ដូចជាឆ្នាំ ២០០០ជាងហ្នឹង ។

ដារ៉ា: គាត់ឈ្មោះអីដែរ ។

សេង: គាត់ឈ្មោះ ហូ សួង ។

ដារ៉ា: មេញពូមានប្រសាសន៍ថា ពូធ្លាប់បម្រើទាហានលន់ នល់?

សេង: បាទ!

ដារ៉ា: កាលហ្នឹងស័ក្តប៉ុន្មានអីប៉ុន្មាន មានស័ក្តទេ?

សេង: អត់ទេ កូនចៅគេទេ ។

ដារ៉ា: កូនចៅគេទេ?

សេង: បាទ! កូនទាហានទេ ។

ដារ៉ា: អញ្ចឹងពួកខ្មែរក្រហមអត់មានស្រាវជ្រាវមកបងប្អូនឪពុកម្តាយ បើដឹងថាពូទាហានលន់ នល់ អញ្ចឹង វាដឹងអត់?

សេង: វាដឹង គ្រាន់តែថាយើងពេលនោះនារតីអត់ទាន់ចុះមក មានតែពួកបងប្អូនវាមានភាពយោគយល់ខ្លះ ហើយខ្ញុំក៏គេចផុតមក ហើយគេក៏មិនរករឿងឪពុកម្តាយខ្ញុំ ។

ដារ៉ា: ហើយកាលហ្នឹងពូមានបានរៀនបានសូត្រដល់ថ្នាក់ណាដែរ?

សេង: ខ្ញុំរៀនបានថ្នាក់ទី៩ចាស់ ។

ដារ៉ា: ៩ចាស់?

សេង: បាទ!

ដារ៉ា: រៀននៅសាលាណាពូ?

សេង: រៀននៅសាលាភ្នំលាភ ភូមិភ្នំលៀប ឃុំភ្នំលៀបហ្នឹង ។

ដារ៉ា: សាលាហ្នឹងសាលាវត្ត ឬក៏សាលាយើង?

សេង: អត់ទេ សាលាយើងធម្មតា ។

ដារ៉ា: ចុះកាលនៅរៀន គ្រូរបស់ពូឈ្មោះអីដែរ?

សេង: គ្រូថ្នាក់ទី១២ឈ្មោះ អ៊ុម សន គ្រូ សន, គ្រូ យន់, គ្រូ កុល, គ្រូ វណ្ណា ក៏ប៉ុន្តែគ្រូទាំង អស់គឺដឹង បើគ្រូ យន់ បើសិនជាគាត់ស្លៀកពាក់ខោត្រីអ៊ីអាខោខ្លីអាវខ្លីហើយមូលដៃ ទៀត ដឹងតែកាចហើយវ៉ៃ ។

ដារ៉ា: គាត់កាច?

សេង: បាទ! គាត់កាច តែដោយសារតែយើងខុសដែរ ខ្ញុំខ្ជិលដែរ ម៉ែឪឲ្យរៀនខ្ញុំមិនចង់រៀន ។

ដារ៉ាៈ អាហ្នឹងធម្មតាទេ ។

សេង៖ បាទ! កាលហ្នឹងវាក្មេង ។

ដារ៉ាៈ ចុះគ្រូទាំងអស់ហ្នឹង ពេលដែលខ្មែរក្រហមចូលមកគាត់ទៅណាមកណា ពូមានដឹងទេ?

សេង៖ គ្រូទាំងអស់ហ្នឹងពេលដែលគេមក គ្រូទៅណាអត់សូវមានកំណត់ទេ ច្រើនតែបញ្ជូនមកពីខាងបាត់ដំបង បញ្ជូនមកខាងណាខាងអីហ្នឹងមក ។

ដារ៉ាៈ កាលមកបង្រៀនជំនាន់ហ្នឹងមែន?

សេង៖ បាទ! មកបង្រៀនហ្នឹង ។

ដារ៉ាៈ ចុះដល់ពេលពួកខ្មែរក្រហមចូលមកដល់ភូមិរបស់ពូហ្នឹង តើគាត់ជម្លៀសទៅណាទៅណើ?

សេង៖ គាត់ទៅភូមិកំណើតគាត់រៀងៗខ្លួន ។

ដារ៉ាៈ អញ្ចឹង?

សេង៖ បាទ! អ្នកដែលបានប្រពន្ធ ខ្លះគេយកប្រពន្ធទៅនៅភូមិកំណើត ប៉ុន្តែមិនដឹងកំណើតគាត់នៅណានៅណើទេ អត់ដឹងទេ ។

ដារ៉ាៈ តែអត់បាននៅក្នុងភូមិហ្នឹងតទៅទៀតទេ?

សេង៖ បាទ! អត់មានបាននៅទេ ។

ដារ៉ាៈ ចុះស្រុកភូមិរបស់ពូ កាលហ្នឹងពូនៅភូមិភ្នំលៀបហ្នឹងហ្នឹង ពេលខ្មែរក្រហមចូលមក ឬក៏យ៉ាងម៉េចពូ?

សេង៖ បាទ! នៅភ្នំលៀប ពេលខ្មែរក្រហមចូលមកដល់ គេជម្លៀសពួកខ្ញុំទៅនៅភូមិកំបោរ ។

ដារ៉ាៈ គេជម្លៀសទៅភូមិកំបោរ?

សេង៖ បាទ! ភូមិកំបោរហ្នឹងឃុំភ្នំលាភដែរ ទៅក្រោម ដល់ពេលគេស្រាវជ្រាវរើទាហានរើអីហ្នឹងខ្ញុំក៏រត់ពីហ្នឹងមកចូលចល័ត ។

ដារ៉ាៈ ចូលចល័ត?

សេង៖ បាទ!

ដារ៉ាៈ ចុះភូមិរបស់ពូនេះ ខាងណាមកនៅវិញកាលជំនាន់ប៉ុល ពត?

សេង៖ មានអ្នកកំបោរ មានកម្មាភិបាលដែលគេរំដោះមុនណ៎ា យើង១៧ មេសា គេជម្លៀសចេញ ពួកគេរំដោះគេមកពីខាងបេងបត់ដង មកពីខាងណាខាងណីច្រើន ។

ដារ៉ាៈ នៅហ្នឹង?

សេង៖ បាទ! សុទ្ធតែកម្មាភិបាល ។

ដារ៉ាៈ អញ្ចឹងប្រជាជននៅភូមិភ្នំលាភហ្នឹងអត់បាននៅភ្នំលាភហ្នឹងទេ គេជម្លៀសទៅនៅភូមិកំបោរ?

សេង៖ បាទ!

ដារ៉ាៈ តែនៅក្នុងឃុំភ្នំលាភដដែល?

សេង៖ បាទ! ជម្លៀសទៅកំបោរ ដល់នៅបានប្រហែលជាជិតមួយឆ្នាំបានគេចេញពីកំបោរមកមកនៅលោតទេ បាត្រង់ សណ្ឋាសអីហ្នឹងតាមដីងស៊ីន ដងស៊ីនរំដួល ។

ដារ៉ាៈ ដងស៊ីនរំដួល?

សេង៖ បាទ!

ដារ៉ាៈ អញ្ចឹងពេលហ្នឹងគឺពូ ដែលគេជម្លៀសទៅភូមិភ្នំលាភហ្នឹង គឺដោយសារពូដឹងខ្លួនថា ពួកខ្មែរក្រហមស្រាវជ្រាវរកទាហានលន់ នល់ មិនអញ្ចឹង?

សេង៖ បាទ!

ដារ៉ាៈ ដល់ពេលអញ្ចឹងពូក៏គេចខ្លួន?

សេង៖ បាទ!

ដារ៉ាៈ គេចខ្លួនចូលចល័ត?

សេង៖ បាទ! ២៨នាក់សល់ប៉ុន្មាន សល់តែខ្ញុំមួយ សល់តែប៉ុន្មានហ្នឹង សល់២-៣នាក់ហ្នឹង ។

ដារ៉ាៈ អ្នកណាខ្លះដែលសល់?

សេង៖ គិតទៅសល់ខ្ញុំមួយ ហើយ អាដេត នោះវាងាប់ដោយសារជម្ងឺរបស់វា បើនិយាយទៅដូចថាសល់ខ្ញុំមួយ អាលឿម២ អាខេង៣ ។

ដារ៉ាៈ លឿម?

សេង៖ បាទ! អាលឿម ហ្នឹងវាធ្វើនគរបាល វាធ្វើប៉ូលីស តែវាសម្រាកហើយ ហើយនៅសល់មួយនោះប្រធាន សព្វថ្ងៃជានាយកសាលាបឋមសិក្សាភ្នំលាភ អាហ្នឹងទាហានជាមួយខ្ញុំដែរតែបានរស់ ចល័តដូចខ្ញុំ ។

ដារ៉ាៈ គាត់ឈ្មោះអីនៅសាលាបឋមសិក្សាភ្នំលាភហ្នឹង?

សេង៖ បើឈ្មោះវាក្រៅផ្លូវការគេហៅ ខេង តែបើឈ្មោះវាដែលវាប្រើជាផ្លូវការឈ្មោះ លីវអ៊ាង ។

ដារ៉ាៈ លីវ អ៊ាង?

សេង: បាទ! លីវ អ៊ាង ហ្នឹងគឺនាយកសាលាបឋមសិក្សាភូមិភ្នំលាភ សល់តែប៉ុន្មាននាក់ហ្នឹងឯង សល់តែ៣នាក់ទេ ។

ដារ៉ា: សល់៣នាក់?

សេង: បាទ! មួយឈ្មោះ ពេជ្រ លឿម ហ្នឹងធ្វើប៉ូលីស តែវាឈប់ហើយ ។

ដារ៉ា: នៅភូមិហ្នឹងដែរ?

សេង: បាទ! នៅភ្នំលាភដូចគ្នា ។

ដារ៉ា: អញ្ចឹងពេលដែលពូចូលចល័តដំបូង ចូលក្នុងកងណា ហើយនៅកន្លែងណា ហើយកាលហ្នឹងឆ្នាំណាពូចូល?

សេង: កាលហ្នឹងខ្ញុំបើគិតទៅវា គេរំដោះឆ្នាំ៧៥ ពេលដែលចូលមកវិបមកគេជម្លៀសចេញទៅក្នុងឆ្នាំ៧៥ដែរ ពេលនោះខ្ញុំរត់មកចូលចល័តហ្នឹង ប្រធានកងហ្នឹងឈ្មោះ តាខូវ ហើយនឹងតាវ៉ន ។ តាវ៉ន ហ្នឹងគាត់អ្នកកំណត់អ្នកកំបោរយើងភ្នំលាភដែរ ។

ដារ៉ា: ប្រធានកងរបស់ពូកងចល័ត?

សេង: បាទ! ប្រធានកងចល័ត ។

ដារ៉ា: កងចល័តហ្នឹងមានស្រីមានប្រុសដែរ ប្រធានកងចល័ត?

សេង: បាទ! មាន ប៉ុន្តែការគ្រប់គ្រងដោយឡែក ប្រុសគឺគ្រប់គ្រងប្រុស ហើយស្រីគឺគ្រប់គ្រងខាងស្រីទៅ ។

ដារ៉ា: ហើយកងចល័តរបស់ពូ ដូចជាទីតាំងអីនៅម្តុំណាដែលបង្កើតកងចល័តហ្នឹង?

សេង: មុនដំបូងមកបង្កើតនៅព្រៃមាន់យើង ។

ដារ៉ា: នៅព្រៃមាន់?

សេង: បាទ! បង្កើតនៅព្រៃមាន់ ហើយរៀបចំកងរៀបចំអីហើយបានចុះទៅក្រោម ទៅកំបោរលើកពីកំបោរស្រះមក ដល់ពេលលើកទំនប់កំបោរស្រះមក វាមាន១៦គីឡូ លើកបានអីរួចអស់ស្រួលបួល បានលើកពីស្រះមកព្រះនេត្រព្រះ ហើយនៅព្រះនេត្រព្រះរួចបានត្រូវ បែងចែកកម្លាំងធ្វើចំការកប្បាសនៅចំការកប្បាសចុះបើសាកពីចុះទៀតបានត្រូវលើកអាង ត្រពាំងថ្ម ។

ដារ៉ា: អញ្ចឹងបើនិយាយទៅ អាហ្នឹងគឺថាកងពូជាប់មករហូតអញ្ចឹងហ្មង?

សេង: បាទ!

ដារ៉ា: ដែលមាន តាខូវ ហើយនឹង តាវ៉ន គឺដឹកនាំរហូតមក?

សេង៖	បាទ!

ដារ៉ា៖	ហើយ តាវ៉ន ហើយនឹង តាខូវ ហ្នឹងគាត់ភាគច្រើនគាត់ទទួលផែនការពីណាមកវិញ?

សេង៖	ទទួលពី តាវ៉ាល់ ។

ដារ៉ា៖	តាវ៉ាល់?

សេង៖	បាទ!

ដារ៉ា៖	ហើយ តាវ៉ាល់ ហ្នឹងគាត់មានឋានៈស្អីដែរ?

សេង៖	ពេលហ្នឹងគាត់ជាអ្នកគ្រប់គ្រងចល័តមួយតំបន់៥ ។

ដារ៉ា៖	មួយតំបន់៥?

សេង៖	បាទ! តំបន់៥ហ្នឹងគឺគាត់ប្រធាន ។

ដារ៉ា៖	តាវ៉ាល់ ហ្នឹងគាត់ប្រធានចល័តតំបន់ តាទេ ឬក៏គាត់ជាប្រធានគេហៅគណៈតំបន់ដែរ?

សេង៖	ដូចជាមិនមែនទេ ព្រោះដំណាក់កាលនោះ ឆ្នាំគណៈតំបន់គឺ តាហឹង ។

ដារ៉ា៖	តាហឹង ហ្នឹងគណៈតំបន់?

សេង៖	បាទ!

ដារ៉ា៖	ហើយមានអ្នកណាទៀត?

សេង៖	ពេលនោះខ្ញុំមិនបានស្គាល់អស់ទេ តែដឹងតែចំនុចមួយគឺ តាហឹង ជាគណៈតំបន់៥ ហើយនឹង តាម៉ង គឺប្រធានស្រុកព្រះនេត្រព្រះ ហើយ តាវ៉ាល់ គាត់ជាប្រធានគ្រប់គ្រងចល័តតំបន់ ។

ដារ៉ា៖	កាលហ្នឹងតំបន់៥?

សេង៖	បាទ!

ដារ៉ា៖	ហើយចុះមកដល់ភូមិភាគឡើងមកលើទៀតពូដឹងទេ ដឹងថាអ្នកណាភូមិភាគ អ្នកណាអនុភូមិភាគដឹងទេ អ្នកណាសមាជិកភូមិភាគទេ?

សេង៖	បើភូមិភាគខ្ញុំស្គាល់តែ រស់ ញឹម មូរ សម្បត្តិ ហៅ ញឹម ។

ដារ៉ា៖	អញ្ចឹងកងចល័តរបស់ពូបានលើកពីភ្នំកំបោរស្រែះមួយដូរហ្នឹងទៅរហូត?

សេង៖	បាទ!

ដារ៉ា៖	ពូរៀបរាប់ម៉េញថាមានប៉ុន្មានគីឡូ?

សេង៖	បើតាមដែល តាវ៉ាល់ គាត់គិតណា៎ គាត់ថា១៦គីឡូ ។

ដារ៉ា៖	ពីណាទៅណាពូ?

សេង: លើកពីស្រះរហូតទៅដល់ហួសកំបោរទៀត គេហៅទំនប់តាបែក ។

ដារ៉ា: ក្នុងរយៈ១៦គីឡូហ្នឹង ត្រូវប្រើពេលវេលាប៉ុន្មានទៅ?

សេង: គិតទៅយូដែរ អាត្រពាំងត្រង់អូររន្ទះបាញ់ហ្នឹង វាលើកនឹងមនុស្សហើយវាជម្រៅចូលទៅក្រោមប្រហែល៣ម៉ែត្រ អាហ្នឹងចំណាយពេលចូលកម្លាំងទាំងអស់ជិតចូលមួយខែជាងគិតទៅចូលជិតមួយឆ្នាំ ក៏ប៉ុន្តែពេលដែលលើកបានហើយវានៅសល់បន្តិចគេទុកកម្លាំងមួយកងពីរកងគ្រាន់ឲ្យបំពេញទៅ ក្រៅពីហ្នឹងគេដកចេញទៅ ។

ដារ៉ា: អញ្ចឹង តាវ៉ាល់ តាអីនេះគាត់ត្រូវមកមើលរឿងលើកទំនប់លើកអីគឺគាត់ហ្នង?

សេង: បាទ! គឺគាត់ ។

ដារ៉ា: អញ្ចឹងពេលម៉ាចូលចល័តមករហូតមកហ្នឹង ដែលថាមកលើកចប់ពីស្រះមកកំបោរហ្នឹង ពូបានធ្វើបានឋានៈបានអីដែរក្នុងពេលហ្នឹង?

សេង: បាទ! ខ្ញុំមានឋានៈជាប្រធានកងធំ ។

ដារ៉ា: ប្រធានកងធំ គ្រប់គ្រងប៉ុន្មានកម្លាំងប៉ុន្មាននាក់?

សេង: គ្រប់គ្រង១០០នាក់ ។

ដារ៉ា: ១០០នាក់ហ្នឹងកងធំ?

សេង: បាទ!

ដារ៉ា: នៅក្នុងឆ្នាំណាដែលពូបានធ្វើប្រធានកងធំ?

សេង: ឆ្នាំ៧៦-៧៧ហ្នឹងឯង ។

ដារ៉ា: ប្រធានកងធំ ហើយចុះអនុប្រធានពូអ្នកណាខ្លះ?

សេង: អនុប្រធានខ្ញុំឈ្មោះ អាស៊ូ ហើយនឹងអា ហូវ ប៉ុន្តែឥលូវគេស្លាប់អស់ហើយ ។

ដារ៉ា: ចុះដល់ពេលដែលពូឡើងជាប្រធានកងធំ តាខូវ ហើយនឹង តាវន ហ្នឹងគាត់មានឋានៈជាអី?

សេង: ប្រធានវរៈសេនាតូច ។

ដារ៉ា: ប្រធានវរៈសេនាតូច?

សេង: បាទ!

ដារ៉ា: កាលហ្នឹងគេហៅដូចរបៀបរចនាសម្ព័ន្ធទាហានអញ្ចឹង?

សេង: បាទ! ប្រធានវរៈ ប្រធានកងតូច ប្រធានកងធំ ។

ដារ៉ា: អញ្ចឹង?

សេង:	បាទ!

ដារ៉ា:	ហើយម៉េចគ្រាន់តែអ្នកលើកចល័តអញ្ចឹងដាក់ដូចទាហានអញ្ចឹង?

សេង:	វាផាយគ្រប់គ្រង វាមានពួកមានក្រុមរបស់គេ ។

ដារ៉ា:	អញ្ចឹង?

សេង:	បាទ! ផាយគ្រប់គ្រង ព្រោះវាមានតាំងពីគេហៅប្រធានក្រុម ។

ដារ៉ា:	បាទ! ប្រធានក្រុម ។

សេង:	ប្រធានក្រុមគេគ្រប់គ្រង១០នាក់ ហើយមានតាំងពីប្រធានពួកទៀត ប្រធានពួកគ្រប់គ្រង ៣នាក់ ។

ដារ៉ា:	៣នាក់?

សេង:	បាទ! ឧបមាថាអូនឯងមួយ ហើយខ្ញុំមួយ អូនឯងប្រធានទៅ ហើយគ្រប់គ្រង២នាក់ទៅ ដូច្នេះវាមាន៣នាក់ ហើយ៣នាក់ហ្នឹង៣បីដងវា៩ហើយ ហើយមានប្រធានមួយទៀត ។

ដារ៉ា:	អាហ្នឹងចូលដល់ប្រធានក្រុម?

សេង:	បាទ! ប្រធានក្រុម ។

ដារ៉ា:	១០នាក់?

សេង:	ប្រធានក្រុមគ្រប់គ្រង១០នាក់ ។

ដារ៉ា:	ទាំងខ្លួនឯង?

សេង:	បាទ! ទាំងខ្លួនឯង១០នាក់ ។

ដារ៉ា:	បន្ទាប់ពីប្រធានក្រុមមក?

សេង:	គេហៅប្រធានកងតូច ប្រធានកងតូចគ្រប់គ្រង៣០នាក់ ។

ដារ៉ា:	៣០នាក់?

សេង:	បាទ!

ដារ៉ា:	បូកទាំងប្រធានហ្នឹងម្នាក់ទៀត?

សេង:	បាទ!

ដារ៉ា:	ឡើងពីកងតូចរហូតដល់កងធំ?

សេង:	កងធំគ្រប់គ្រង៩០នាក់ ហើយ៩០នាក់ហ្នឹងមានបែងចែកទៅជាដាំបាយ រកត្រីនាយអាយ ហើយវាគ្រប់១០០នាក់ ១០០ទាំងយើង ។

ដារ៉ា:	ហើយកងធំអញ្ចឹង ឡើងពីកងធំមក?

សេង: អត់ទេ ។

ដារ៉ា: អត់ទេ ខ្ញុំចង់និយាយពីរចនាសម្ព័ន្ធវាណា៎?

សេង: ឡើងកងធំហ្នឹងចូលវរៈសេនាតូច ។

ដារ៉ា: វរៈសេនាតូច?

សេង: បាទ!

ដារ៉ា: វរៈសេនាតូចហ្នឹងមានប៉ុន្មានកងពល?

សេង: វាមាន៣កងធំ ។

ដារ៉ា: អញ្ចឹងឡើងពីវរៈសេនាតូច?

សេង: វាមានវរៈសេនាធំ ។

ដារ៉ា: វរៈសេនាធំមានប៉ុន្មានវរៈសេនាតូច?

សេង: ៣វរៈសេនាតូចបាន១វរៈសេនាធំ ។

ដារ៉ា: អញ្ចឹងកាលហ្នឹងអត់ទាន់ដល់កងពលទេ?

សេង: អត់ទេ គេរៀបចំតែប៉ុណ្ណឹងទេ បើរៀបចំត្រឹមតែវរៈសេនាតូចទី១ វរៈសេនាតូចទី២ វរៈសេនាតូចទី៣ ដូច្នេះក្នុងវរៈសេនាតូចគឺគ្រប់ត្រឹមតែ៣០០ ដូច្នេះគ្របលើមនុស្សគឺគាវ៉ាល់គ្រប់គ្រងវរៈសេនាតូចទាំងអស់ ។

ដារ៉ា: អញ្ចឹងពូ នៅក្នុងកងធំរបស់ពូមិននៅក្រោមវរៈសេនាតូច មិនអញ្ចឹង?

សេង: បាទ! ក្រោម ។

ដារ៉ា: វរៈសេនាតូចហ្នឹងទីប៉ុន្មាន?

សេង: ខ្ញុំវរៈសេនាតូចទី១ ។

ដារ៉ា: ហើយអ្នកណាប្រធានវរៈសេនាតូច?

សេង: ប្រធានគឺ តាខូវ ហើយរងគឺ តាវ៉ន ។

ដារ៉ា: អញ្ចឹងគាត់ហ្នឹងឯងប្រធានវរៈសេនាតូច?

សេង: បាទ!

ដារ៉ា: អញ្ចឹងពល់កាធ្វើផែនការ ឬក៏វាយការណ៍អីគេវាយការណ៍យ៉ាងម៉េច?

សេង: អាហ្នឹងយើងប្រធានកងអនុសេនាធំវាយការណ៍ឲ្យប្រធានវរៈសេនាតូច ។

ដារ៉ា: ការវាយការណ៍ហ្នឹងច្រើនធ្វើតាមរបៀបម៉េច?

សេង: បើសិនជាខ្វះគេច្រើនរើសអ្នកដែលមិនចេះអក្សរ ។

ដារ៉ា: ម៉េចអញ្ចឹង?

សេង: ព្រោះបើកាលណាយើងចេះអក្សរយើងចេះអីទៅដូចថាគេមិនសូវប្រើ ហើយយើងប្រឆាំងហ្នឹងអង្គការ យើងវាចេះរកអ្នកដែលមិនចេះអក្សរ ហើយជាពិសេសរកអ្នករាយការណ៍ផ្ទាល់ មាត់បានល្អ បើកាលណាយើងចេះអក្សរគេថា គេមិនសូវយកផង គេយកតែអ្នកល្ងង់ទេ ហើយនឹងអ្នកក្រទេយកមកធ្វើការ ។

ជាតា: ម៉េចបានគេយកអ្នកល្ងង់ ដូចថាស្មោះឬក៏ម៉េចពូ?

សេង: វាងាយក្ជួយ វាត្រង់ថាឲ្យសម្លាប់បងវាក៏វាហ៊ាន ឲ្យសម្លាប់ប្អូនវាក៏វាសម្លាប់ សម្លាប់ឪវាក៏វាសម្លាប់ បើអ្នកចេះវាពិចារណា មុននឹងលើកដៃវ៉ៃឪក៏វានឹកឃើញថាអ៎! ពុកអញម៉ែអញអ្នកមានគុណ មុននឹងវ៉ៃប្អូនឯងបងឯងក៏វាចេះគិតអ៎អានេះភូមិផងរបងជាមួយ សាច់ញាតិបងប្អូន អញ្ចឹងបានគេអត់យក គេចូលចិត្តយកអាណាដែលព្រុសហើយខាំណា៎ គ្រាន់តែព្រុសហើយខាំហ្នង ហើយគេអត់គិតបងគិតប្អូនទេ គិតតែអាហ្នឹងគឺខ្ទាំង ខ្ទាំងជាមួយ អង្គការ វាស្រួលប្រើអញ្ចឹងណា៎ ។

ដារ៉ា: អញ្ចឹងពូ ការរាយការណ៍របស់ពូទៅប្រធានវរៈសេនាតូចអីហ្នឹង ភាគច្រើនធ្វើផ្ទាល់មាត់ទេ?

សេង: បាទ! ភាគច្រើនគឺផ្ទាល់មាត់ ។

ដារ៉ា: អត់មានជាឯកសារអីទេ?

សេង: អាចមានខ្លះ ។

ដារ៉ា: មានខ្លះដែរ?

សេង: បាទ! ក៏ប៉ុន្តែដែលមានខ្លះហ្នឹងខ្ញុំគ្រាន់តែចេះសរសេរបានអានបានដែរណា៎ ក៏ប៉ុន្តែមានមួយហ្នឹងវាគ្រាន់ដូចថាឲ្យគេសរសេរយើងមានគំនិតអញ្ចឹងណា៎ បងប្អូនមកពីភ្នំពេញគេអ្នកចេះ ។

ដារ៉ា: ឈ្មោះអីទៅពូ?

សេង: ខ្ញុំហៅតែ អាម៉ាប់ៗ ឈ្មោះពិតប្រាកដមិនដឹងជាឈ្មោះអី វាធំត្រឡោកហើយវាត្រម៉ាប់ ដល់ហើយខ្ញុំហៅវា អាម៉ាប់ ទៅ ហើយខ្ញុំប្រាប់ថារាយការណ៍ថាថ្ងៃនេះអវត្តមានប៉ុណ្ណេះ វត្តមានប៉ុណ្ណេះ ហើយដីបានប៉ុន្មានម៉ែត្រគីបប៉ុណ្ណេះ ហើយវាសរសេរទៅ ហើយខ្ញុំយក ទៅឲ្យទៅ ។

ដារ៉ា: ហើយនៅក្នុងកងពូហ្នឹងមានអ្នកជម្លៀសមកពីក្រៅច្រើនទេ?

សេង៖ ភាគច្រើនគឺអ្នកហ្នឹងឯង មូលដ្ឋានគឺមានតែខ្ញុំ៣នាក់ទេជាប្រធានហ្នឹងឯង ក្រៅពីហ្នឹងគឺអ្នកភ្នំពេញទាំងអស់ ។

ដារ៉ា៖ ពូអាចនៅចាំឈ្មោះ អ្នកណាខ្លះដែលជម្លៀសមកពីភ្នំពេញ ទោះបីជាឈ្មោះពិតប្រាកដ ឬក៏ឈ្មោះហៅក្រៅក៏ដោយ ពូអាចជួយរកនឹកមើលអាចចាំបានប៉ុន្មាននាក់ដែរ?

សេង៖ ខ្ញុំគិតទៅ ដល់ពេលយូទៅបើសិនជាខ្ញុំចាំបានមាន ស៊ីម គឹមថៃ នីង ម៉ែន ស៊ីផាន់ អាហ្នឹងគឺគាត់នៅផ្ទាល់ជាមួយខ្ញុំរាល់ថ្ងៃ គាត់ដាំបាយ គាត់រកត្រី រកម្ហូប ហើយក្រៅពីនោះមានអាម៉ាប់ មានអាអីៗច្រើន វាចូល១០០នាក់ហើយ ចាំមិនបានអស់ទេ ។

ដារ៉ា៖ ហើយចុះសម្រាប់ប្រធានក្រុមប្រធានពួកអីហ្នឹងគេរាយការណ៍យ៉ាងម៉េចតទៀត?

សេង៖ អាហ្នឹងរាយការណ៍ឲ្យមក ។

ដារ៉ា៖ តៗគ្នាទៅ?

សេង៖ បាទ! ពេលដែលយើងនេះទៅ យើងវាអត់ចាំណា៎ ហ៎! ក្រុមហ្នឹងគេរាយការណ៍ឲ្យកងតូចប្រធានកងតូចគេរាយការណ៍ឲ្យយើង ហើយរាយការណ៍ឲ្យប្រធានកងធំ យើងចុះទៅបីយើងចាំព្រោះយើងសរសេរទៅ ហ៎! កងតូចទី១កម្លាំងប៉ុណ្ណេះៗ កងតូចទី១ប៉ុណ្ណេះ កងតូចទី៣ប៉ុណ្ណេះ សរុបប៉ុណ្ណេះៗយើងរាយការណ៍ឲ្យទៅវរៈ ។

ដារ៉ា៖ អញ្ចឹងម៉ាក្នុងដំណាក់កាលទី១ដែលលើកទំនប់ពីស្រែះមកដល់កំបោរមកដល់អីនេះ អាហ្នឹងកាហូបចុក កាស្នាក់នៅយ៉ាងម៉េចដែរពេលហ្នឹង ហើយការគ្រប់គ្រងជាដើម?

សេង៖ ពេលហ្នឹងយើងនៅបបូរ ទុកថាបបូរចុះ ព្រោះដំណាក់កាលហ្នឹងគេគិតណា៎ អ្នកដែលរែកដីចាប់ពី៤ម៉ែត្រគីបឡើងដល់៥ម៉ែត្រគីបបាយហូបម៉ាឆ្អែត ២-៣ពេលក៏បាន ហូបតាមចិត្តទៅ អាហ្នឹងចាប់ពី៤ម៉ែត្រគីបឡើង ហើយត្រីផ្សេងៗគេបុកឲ្យទាំងគីឡូៗធ្វើការទាំងយប់ទាំងថ្ងៃទៅ ហើយបើ៣ម៉ែត្រគីបចុះក្រោម ត្រឹម២-៣ហ្នឹងអាហ្នឹងគេហៅកណ្ដាល អានោះវា មិនបាននេះទេ គេបើកឲ្យតែមួយថ្ងៃ២កំប៉ុង ។

ដារ៉ា៖ អង្ករមែន?

សេង៖ បាទ! មួយថ្ងៃ២កំប៉ុង ។

ដារ៉ា៖ របប?

សេង៖ បាទ! របបមួយថ្ងៃ២កំប៉ុង អាហ្នឹងត្រឹម២ម៉ែត្រគីប ហើយបើសិនជាត្រឹម៤ម៉ែត្រគីបឡើងទៅអាហ្នឹង៤កំប៉ុងឡើងមួយថ្ងៃ ។

ដារ៉ា៖ ចុះបើក្រោម?

សេង៖	អាក្រោមហ្នឹងទៀត អាហ្នឹងនៅត្រឹមមួយកំប៉ុង អាហ្នឹងដូចថាវាគ្រាន់តែអន្តុយវ៉ៃដើងទំនប់ ក្អែកម្អួបក្អែកអីរកតែធ្វើការមិនកើត មួយកំប៉ុងទៅមួយថ្ងៃ ។

ដារ៉ា៖	អញ្ចឹងកំណត់របបអញ្ចឹង អ្នកណាជាអ្នកកំណត់មក?

សេង៖	ពេលហ្នឹងមានអាគេអ្នកនេះដែរ អ្នកបើកអន្ទរបើកអីណា ហើយខ្ញុំក៏មិនដែលបានទៅជិតទៅអីដែរ ប៉ុន្តែគ្រាន់តែយើងខាងដាំបាយយើងដឹង ថាក្នុងមួយវេះយើងមានប៉ុណ្ណេះៗទៅយកនេះទៅឲ្យគេទៅគេបើកឲ្យហើយ ។

ជាតា៖	អញ្ចឹងក្នុងកងពួមានគ្រប់ប្រភេទ មានទាំងអ្នកលើក៥ម៉ែត្រគីប ៣ម៉ែត្រគីប ហើយនឹងអ្នកក្រោមហ្នឹងទៀត?

សេង៖	ហ្នឹងហើយ ។

ជាតា៖	មានគ្រប់ប្រភេទទាំងអស់?

សេង៖	បាទ! ៣ ។

ដារ៉ា៖	អញ្ចឹងការហូបចុកអី ហូបខុសៗគ្នា?

សេង៖	ខុសគ្នា ។

ដារ៉ា៖	តាម៣ប្រភេទហ្នឹង?

សេង៖	បាទ!

ដារ៉ា៖	អញ្ចឹងពួកដែលលើកពី៣ទៅ៥ម៉ែត្រគីបហ្នឹងគេហូបមួយក្រុមគេទៅ?

សេង៖	បាទ! អាហ្នឹងគឺប្រធានកងគេផ្សេង ។

ដារ៉ា៖	អ៎! គេមានកងគេផ្សេង?

សេង៖	បាទ! ឧបមាថាកងខ្ញុំ១០០នាក់ ដល់ពេលអ្នកណាដែលលើកខ្លាំងអញ្ចឹងទៅ ។

ដារ៉ា៖	គេដាក់មួយកង?

សេង៖	បាទ! ដូចថាអានេះបានប៉ុណ្ណេះ អានេះបានប៉ុណ្ណេះដែរវាអត់បានដល់១០០នាក់បានតែត្រឹម៥០-៦០នាក់អាហ្នឹងគេដាក់មួយកងផ្សេង រើសមកងមួយផ្សេង ដូច្នេះគេបើកឲ្យអាក្រុមដែលខ្លាំងហ្នឹងបើករបបផ្សេង ហើយយើងនៅសល់តែអានេះគេបើករបបឲ្យផ្សេងទៀត ។

ជាតា៖	ដល់បើករបបហើយឋិតនៅក្រោមពួគ្រប់គ្រងដដែល?

សេង៖	អត់ទេ! ដល់ពេលអញ្ចឹងកម្លាំងដែលខ្លាំងគេយកទៅផ្សេង គេរើសប្រធានកងទៅផ្សេង ហើយខ្ញុំដាច់ហើយ ។

ជាតា: ចុះពូគ្រប់គ្រងកងកម្រិតណា?

សេង: ខ្ញុំនៅកម្លាំងទី២ អាយើងត្រឹម២-៣ម៉ែត្រចុះក្រោម ១ម៉ែត្រ ២ម៉ែត្រ ៣ម៉ែត្រ អាហ្នឹងពួកខ្ញុំហើយ ។

ដារ៉ា: អញ្ចឹងបន្តទៀតពូ ចប់ពីស្រែះមកកំបោរហ្នឹងហើយ ពូបន្តទៅណាទៀត?

សេង: ពីហ្នឹងខ្ញុំមកនៅធ្វើចំការកប្បាស់នៅជប់ ។

ដារ៉ា: នៅជប់?

សេង: ចំការកប្បាសជប់ស្រុកយើងនេះណា៎ ។

ដារ៉ា: អាហ្នឹងវានៅក្នុងឆ្នាំណា?

សេង: អាហ្នឹងដូចជាឆ្នាំចូល៧៧ហើយ ៧៧ហ្នឹងហើយ ។

ដារ៉ា: ហើយធ្វើនៅចំការកប្បាសហ្នឹង នៅជប់ហ្នឹងរយៈពេលប៉ុន្មានដែរពូ?

សេង: ធ្វើម៉ាដាំហ្នឹងមិនបានយូទេ ថែដងអីជង មើលទៅខ្ទង់ជា៣-៤ខែ ។

ដារ៉ា: អញ្ចឹងមានន័យថានៅពេលដែលកប្បាសហ្នឹងបានផលហើយឬក៏យ៉ាងម៉េច?

សេង: អត់ទេ កប្បាសហ្នឹងវាអត់ទាន់បានផលទេ ដូចថាវាដុះមកយើងដឹងថារួចខ្លួនហើយណា៎ វាឈប់មានអីទៀតទៅ បានគេដកខ្ញុំមកធ្វើនៅអាងត្រពាំងថ្ម ហើយទុកកម្លាំងមួយចំនួនសម្រាប់បាញ់ថ្នាំ បាញ់ថ្នាំកប្បាសកុំឲ្យដង្កូវស៊ី ។

ដារ៉ា: អញ្ចឹងកប្បាសនេះ កងដែលមាននៅប៉ុន្មានគឺលើកពីស្រែះមកកំបោរហ្នឹងគឺមកដាំកប្បាសទាំងអស់ឬក៏យ៉ាងម៉េច?

សេង: ពេលហ្នឹងដាំនៅហ្នឹងមួយចំនួន គេដកទៅនៅសាលាក្រហម សាលាក្រៅយើងនេះជិតស្វាយ គេដកទៅនៅហ្នឹងម៉ាចំនួនធ្វើស្រែ ។

ដារ៉ា: អញ្ចឹងមានម៉ាចំនួនទៅធ្វើស្រែនៅសាលាក្រៅ ហើយម៉ាចំនួនដាំកប្បាស?

សេង: បាទ! ដាំកប្បាស ។

ដារ៉ា: ហើយកងរបស់ពូមកដាំកប្បាស?

សេង: បាទ! ដាំកប្បាស ។

ដារ៉ា: អញ្ចឹងកងហ្នឹងនៅតែ តាខូវ ហើយនឹង តាវ៉ន ដដែលទេ?

សេង: បាទ! គាត់ជាអ្នកគ្រប់គ្រងដដែល ។

ដារ៉ា: អញ្ចឹងដាំបានត្រឹមកប្បាសវាលូតលាស់ហើយ មើលថាទៅមុខហើយក៏ដកមកលើកអានត្រពាំងថ្ម?

សេង: បាទ! ដកមកលើកអាងត្រពាំងថ្ម។

ដារ៉ា: អញ្ចឹងយើងមកដល់ដំណាក់កាលអានត្រពាំងថ្មម្តង?

សេង: បាទ!

ប្រុញ: អត់ទោស! សុំសួរពាក់ព័ន្ធកន្លែងចំការកប្បាសហ្នឹងថាមានខាងចិនខាងអីមក?

សេង: ពេលនោះគឺមានជំនាញការរបស់ចិន។

ប្រុញ: ជំនាញការរបស់ចិន?

សេង: បាទ!

ដាតា: វាមកចាំដាំហ្នុង?

សេង: អត់ទេ វាអត់មានមកចាំដាំទេ គឺវាមកមើលហើយវាប្រាប់ហ្នុង។

ប្រុញ: ពីណាអ្នកនាំគាត់មកពូ?

សេង: កាលដែលនាំមកគឺមិនបានដឹងទេ មិនដឹងអ្នកណាទេ ប៉ុន្តែយូណាស់ទើបគេមកម្តង ជួនកាលទៅវាអត់ទៀងទេ ជួនកាលមួយខែគេមកម្តង ជួនកាល២-៣ខែគេមកម្តងក៏មាន ឡានគេមកអីមក គេមិនដែលដេកហ្នឹងទេ គេមកមើលតែ១ម៉ោង២ម៉ោងប្រាប់អីអញ្ចេះអញ្ចុះនាយ អាយ ហើយគេទៅដេកនៅស្វាយ អាកន្លែងទទួលភ្ញៀវគេណា៎។

ប្រុញ: អញ្ចឹងសុទ្ធតែអ្នកជំនាញការមកដាំ ហើយប្រាប់យើងដាំម៉េចអីម៉េចហ្នឹងពូ?

សេង: បែបអញ្ចឹងឯង ព្រោះយើងអត់ហ៊ានជិតគេ ធ្វើឆ្ងាយតែយើងដឹងថាគេចិន ហើយឲ្យតែវាមកវាប្រាប់តែអ្នកដែលដាំអ្នកដែលអីនោះណា៎ អត់មានថាដាំអញ្ចេះ លាយថ្នាំបាញ់អញ្ចេះ ហើយគេក៏ទៅវិញទៅ ទៅដេកនៅស្វាយទៅ។

ប្រុញ: អញ្ចឹងគេមកញឹកញាប់ដែរពូ?

សេង: អត់ទៀងដែរ ជួនកាលបើឃើញ ឃើញតែអាកប្បាសដែលយើងដាំបានហើយគេមកអ៊ើតម្តងទៅ អាកប្បាសដែលវាជិតចេញផ្លែមកម្តងទៅ ដល់ពេលគេបាញ់ថ្នាំហើយកប្បាសវាទុំគេមកម្តងទៀតទៅ មកពីបីដងគេឈប់ហើយ ហើយយើងធ្វើខ្លួនយើង។

ដារ៉ាៈ អញ្ចឹងខ្ញុំសុំសួរបកក្រោយមួយម៉ាត់ពីរទៀត ទាក់ទងនឹងការលើកទំនប់នៅស្រះរហូតមកដល់កំប្បោរណាពូ នៅពេលដែលលើកហ្នឹងដូចថាការផ្គត់ផ្គង់ ហើយការហូបចុកអីហ្នឹង អាហ្នឹងមកពីខាងណាវិញ?

សេងៈ អាហ្នឹងគឺឡានដឹកមក តែមិនដឹងដឹកមកពីណា ហើយពេលយកទៅដល់គឺដុកក្នុងឃ្លាំង ហើយមានរោងម៉ាស៊ីនមួយទៅ ហើយមានអីគេយកទៅដុកនៅហ្នឹងទៅ ហើយយើងវេរៈដូចថាយើងនៅឆ្ងាយមានរទេះគោមានអីដឹកយកទៅទុកទៅ ប៉ុន្តែមិនដឹងដឹកពីណា អត់ដឹងទេ។

ដារ៉ាៈ តែអ្នកដែលលើកទំនប់ហ្នឹងគឺមួយថ្ងៃដឹងតែលើកទំនប់ហ្នឹងទៅ?

សេងៈ បាទ! គិតតែពីលើកហ្នឹងឯង។

ដារ៉ាៈ ចុះទាក់ទងនឹងរឿងលើកទំនប់ហ្នឹងដែរ គឺថាមានតែកងពូមានអ្នកមកពីជម្រៀសមកពីណាផ្សេងៗក្នុងកងហ្នឹងទេ?

សេងៈ គេច្រើនតែថា ជួនកាល១៧ មេសា ប្រជាជនថ្មីណា៎ ប៉ុន្តែនិយាយទៅគឺមកតែពីភ្នំពេញហ្នឹង ហើយមិនដឹងមកពីណាពីណីខ្លះសុទ្ធតែបងប្អូនមកពីភ្នំពេញ ប៉ុន្តែនៅជាមួយខ្ញុំសួរទៅថានៅអង្គស្នួល ខ្លះសួរទៅថានៅស្អីណាខេត្តកណ្ដាល ខ្លះថា ព្រៃវែង ស្វាយរៀង តាកែវ តែបើយើងមិនដឹងថានៅភ្នំពេញទាំងអស់ហ្នឹង។

ដារ៉ាៈ ហើយចុះអ្នកទាំងអស់ហ្នឹងអាចលើកអាចអីបានដូចពូដូចអីដែរ?

សេងៈ ខ្លាំង។

ដារ៉ាៈ ខ្លាំង?

សេងៈ បាទ!

ដារ៉ាៈ ខ្លាំងបានតែមុនដំបូងប្ដូរក៏យ៉ាងម៉េច?

សេងៈ អត់ទេ គឺវាអញ្ចេះ វាដល់មកបើអ្នកដែល ជួនកាលចេះណា៎ ក៏ប៉ុន្តែធ្វើល្ងង់ធ្វើអីទៅបានរស់ ខំរែកខំអីទៅអ្នកណានេះក៏បានរស់ទៅ អ្នកដែលចេះគេរែក មិនដែលអ្នកណាប្រើមនុស្សចេះទេ ទាមទារឲ្យគេលើកអនុវិទ្យាល័យ វិទ្យាល័យ និសិត្ស ហើយសួរទៅសុទ្ធតែនិសិត្ស គេមានបណ្ដាញប្រវត្តិគេឲ្យធ្វើទៅណា៎ ហើយគេឲ្យធ្វើប្រវត្តិរូបធ្វើអីទៅ។

ដារ៉ាៈ ពូដឹងដែរពូ?

សេងៈ ខ្ញុំអត់បានដឹងទេ ប៉ុន្តែខ្ញុំក៏បានស្ដាប់គេខ្លះៗដែរ ខ្ញុំថាធ្វើអញ្ចឹងអត់បានទេសម័យនេះ ខ្ញុំរត់ចេញមកដោយសារខ្ញុំគេចពីទាហានណា៎។

ដារ៉ាៈ ប្រាប់អញ្ចឹងហ្មង?

សេង៖ បាទ! ប្រាប់ត្រង់ កុំអត់បានទេ ។

ដាតា៖ ប្រាប់កូនក្រុមពូមែន?

សេង៖ បាទ! ប្រាប់កូនក្រុមក្រោមការគ្រប់គ្រងរបស់ខ្ញុំ ប៉ុន្តែគេក្នុងនោះគេមាន២-៣នាក់ ចុះតាមកងជាសម្ងាត់របស់គេ ។

ដារ៉ា៖ អាហ្នឹងមួយជាន់ទៀតហើយ?

សេង៖ បាទ! ឥលូវខបមាថា ខ្ញុំអញ្ចេះ មកដល់ឃើញវែកជួយកាប់ដី បើគេមិនបានវែកគេមិនសួរ វែកទេ គ្រាន់តែកាប់ដីហើយគេសួរ បងឯងនៅណា មិត្តឯងនៅណា?

ដារ៉ា៖ គេសួរដែរ?

សេង៖ បាទ! គេសួរអញ្ចឹងណា៎ មិត្តឯងនៅណា ហើយពីដើមធ្វើអី យើងហ្នឹងឆ្លោយមាត់ខ្ញុំហ្នឹងមិន ដែលកំសត់ទេ ប៉ុខ្ញុំឲហាន ហើយខ្ញុំចេះៗ អាហ្នឹងអត់យូទេបាត់ខ្លួន ។

ដារ៉ា៖ ចុះនៅក្នុងកងរបស់ពូហ្នឹងមានបាត់ខ្លួនមនុស្សប្រភេទអញ្ចឹងៗដែរ?

សេង៖ បាត់៣នាក់ ។

ដារ៉ា៖ បាត់៣នាក់?

សេង៖ បាទ!

ដារ៉ា៖ ម៉ារយៈពេលដែលលើកទំនប់ពីស្រែះមកកំបោរហ្នឹងពូថាបាត់៣នាក់?

សេង៖ បាទ! អត់ទេ អានេះមកបាត់នៅអាងត្រពាំងថ្មហ្នឹង ។

ដារ៉ា៖ បាត់នៅអាងត្រពាំងថ្ម ហើយចុះកាលនៅស្រែះហ្នឹងអត់មានបាត់ទេ?

សេង៖ អត់ទាន់មានបាត់ទេ អត់ទាន់បាត់ខ្លាំងទេ នៅធម្មតាទេ មកបាត់នៅត្រពាំងថ្មនេះហ្នឹង៣ នាក់ ។

ដារ៉ា៖ អញ្ចឹងពូ ពេលពូរៀបរាប់មកដល់កន្លែងត្រពាំងថ្ម ពូមកដល់កន្លែងត្រពាំងថ្មហ្នឹងគឺកងរបស់ពូដដែលទេដែលមកដល់ត្រពាំងថ្មហ្នឹង?

សេង៖ បាទ! កងរបស់ខ្ញុំ ។

ដារ៉ា៖ អញ្ចឹងពូថានៅក្នុងឆ្នាំ៧៧?

សេង៖ បាទ! ៧៧ ។

ដារ៉ាៈ អញ្ចឹងមកដល់ឆ្នាំ៧៧ មកដល់កន្លែងត្រពាំងថ្មមុនមានទទួលផែនការយ៉ាងម៉េចដែលមកដល់ ត្រពាំងថ្មហ្នឹង?

សេងៈ ពេលនោះផាកចេញពីជប់មកអត់ដឹងរឿងទេ ក៏ប៉ុន្តែប្រធានវរៈប្រាប់ថាហៅប្រធានកងធំប្រាប់ថាឲ្យរៀបចំឥវ៉ាន់ ព្រោះស្អែកយើងត្រូវទៅទៀតហើយ រើកន្លែងទៅទៀត ហើយថាទៅណាអ៊ឺ ហើយខ្ញុំថាអញក៏មិនទាន់បានសួរអង្គការទេ ចាំអញសួរអង្គការសិន ហើយអង្គការក៏អត់ប្រាប់ ឈ្មោះ តាវន ហើយនឹង តាខូវ គាត់ថារៀបចំទៅ ព្រឹកនេះយើងអត់បាននៅទេ គាត់ពីថ្ងៃនេះ ស្អែកយើងអត់បាននៅទេត្រូវរើទៅទៀត ហើយថារើទៅណាបងមិនដឹងទេអញមិនទាន់បានសួរអង្គការទេ ហើយខ្ញុំក៏មិនដឹងដែរ ។

ដារ៉ាៈ អញ្ចឹង?

សេងៈ បាទ! គេអត់ប្រាប់យើងថាទៅនេះទៅនោះទេ គេអត់មានប្រាប់ទេ ពេលដែលឡើងឡានឡើងត្រាក់ទ័រទៅបានយើងដឹងថានៅទីនេះនៅទីនោះ ។

ដារ៉ាៈ អញ្ចឹង?

សេងៈ បាទ!

ដារ៉ាៈ អញ្ចឹងពូ ពីកំបោរពីអីទៅ អាស់! ចេញពីកប្បាស កន្លែងដាំកប្បាសណាំនៅជប់ទៅត្រពាំងថ្មហ្នឹងពូជិះអីទៅ?

សេងៈ ពេលហ្នឹងគឺជិះត្រាក់ទ័រ ។

ដារ៉ាៈ ជិះត្រាក់ទ័រមួយកងពូមែន?

សេងៈ បាទ!

ដារ៉ាៈ ខ្ញុំទៅកន្លែងព្រះនេត្រព្រះហ្នឹងជួប ពូយឿង ខ្ញុំសម្ភាសន៍ប្រពន្ធគាត់ ។

សេងៈ ប្រពន្ធគាត់នៅជាមួយខ្ញុំដែរ ។

ដារ៉ាៈ ហ្នឹងហើយ មីង បណ្ដែត ហ្នឹង ។

សេងៈ អាហ្នឹងគេប្រធាននារី ខ្ញុំប្រធានយុទ្ធជន នៅជាមួយហ្នឹងមាន មីណែត ហ្នឹងមួយ ហើយមីលឿង មួយ នៅផ្ទះក្បែរគ្នាហ្នឹង ប៉ុន្តែគេប្រធាននារីហើយខ្ញុំប្រធានយុទ្ធជន ។

ដារ៉ាៈ និយាយបន្តិចចុះ កាលហ្នឹងប្រធានគេអត់ទាក់ទងគ្នាទេ?

សេងៈ ជាពិសេសគឺប្រធានហ្នឹងឯង មុនដំបូងយើងហៅកូនចៅប្រជុំជីវភាពរស់នៅប្រចាំថ្ងៃ គោលដំហរសតិអារម្មណ៍ សិលធម៌អី ប៉ុន្តែយើងថាគេមិនឲ្យគេទៅលេងកន្លែងស្រី តាមពិតប្រធានកងទៅលេង វាអញ្ចឹងឯងណាំ យើងដូចថាវាធំហើយ ។

ដារ៉ា: កាលហ្នឹងដូចថាមីង ដែត ហ្នឹងស្អាតណាស់ ពេលស្លៀកខ្មៅអីឡូយណាស់ ។

សេង: មិត្តនារី ។

ដារ៉ា: មិត្តនារីហ្នឹងឡូយណាស់ ល្បីម៉ាព្រះនេត្រព្រះ ។

ប្រពន្ធ: គាត់ហ្នឹងអ្នកល្អចស្រលាញ់គេ ។

សេង: ស្រលាញ់អី ។

ដារ៉ា: មេកង១ គេទាក់ទងគ្នា ។

ដាតា: ប្តីគាត់ជាអីទៅពូបានគាត់អញ្ចឹង?

សេង: អត់ទេ អាហ្នឹងកំណើតវាអ្នកស៊ីងកំបុត អ្នកអីផ្សេងទេ បានវៀតណាមចូលមក ។

ដារ៉ា: ត្រពាំងថ្ម អញ្ចឹងអាផែនការទៅហ្នឹងយើងអត់ដឹងទេពូណោះ?

សេង: បាទ!

ដារ៉ា: អត់ដឹងថាត្រូវទៅត្រពាំងថ្ម យើងអត់ដឹងទេ ទាល់តែទៅដល់កន្លែងហ្នឹងហ្នងបានដឹងថា ត្រពាំងថ្ម?

សេង: បាទ!

ដារ៉ា: ហើយពូថាជិះត្រាក់ទ័រទៅកន្លែងហ្នឹងទៀត?

សេង: បាទ!

ដារ៉ា: ទៅដល់ដំបូង កាលហ្នឹងពូអាចបញ្ជាក់ឡើងវិញបានទេថា ឆ្នាំណាដែលទៅកន្លែងហ្នឹង?

សេង: អាហ្នឹងឆ្នាំ១៩៧៧ ។

ដារ៉ា: អាចថាដើម កណ្តាល ឬក៏ចុងឆ្នាំ?

សេង: ពេលហ្នឹងវាដូចជាភ្លេចដែរ ចាំបានត្រង់ថា៧៧ បើដើមចុងអីហ្នឹងមិនចាំទេ ។

ដារ៉ា: ចុះកាលហ្នឹងបើយើងនិយាយពីរដូវវិញវាត្រូវរដូវស្អី?

សេង: រដូវយើងគិតទៅធ្វើបានឡើងយូហើយបានគេធ្វើស្រែ គិតទៅប្រហែលជាយើង វាពិបាក ដែរហ្នឹង ប៉ុន្តែខ្ញុំវាចាំអត់បាន ។

ដាតា: ខែភ្លៀងមែនពូ?

សេង: ធ្វើបានប្រហែលខ្លងមួយខែហើយបានមានភ្លៀងធ្លាក់មកបណ្តើរៗ ។

ដារ៉ា: អញ្ចឹងវាអាចចូលក្នុងខែ៧-៨ ជាទូទៅភ្លៀងធ្លាក់ក្នុងខែ ។

សេង: យើងជិះត្រាក់ទ័រទៅធ្វើបានប្រហែលជាមួយខែជាងហើយហ្នឹងបានមានភ្លៀង ។

ដារ៉ា: អញ្ចឹងពេលទៅដល់កន្លែងត្រពាំងថ្មដំបូងហ្នឹងអត់ទាន់មានភ្លៀងទេ?

សេង: អត់ទេ អត់ទាន់មានទេ ។

ដារ៉ា: នៅរាំងទេ?

សេង: បាទ! នៅរាំង ។

ដារ៉ា: ហើយធ្វើបានមួយខែពីរខែបានចាប់ផ្ដើមមានភ្ញៀវ?

សេង: បាទ!

ដារ៉ា: អញ្ចឹងកាលទៅដំបូងហ្នឹងអត់មានភ្ញៀវទេ?

សេង: អត់មានទេ ។

ដារ៉ា: អញ្ចឹងប៉ុណ្ណឹងក៏បានដែរ ព្រោះយើងមិនចាំ យ៉ាងហោចណាស់ក៏ដឹងថាអត់មានភ្ញៀវមានអីអញ្ចឹងដែរ នៅក្នុងរដូវប្រាំង ។ ចុះពេលទៅដល់ដំបូងហ្នឹងពូអត់មានរូបរាងអីជាទំនប់ជាអាងអីទេពូ?

សេង: អត់ទេ វាព្រៃណា៎ បើយើងជនបទគេហៅដុប ដល់យើងនោះគេហៅព្រៃ ព្រៃវាទៅលិចដាច់កន្ទុយភ្នែកប៉ិតហ្នឹង ហើយសងខាងក៏មានស្រែ មានប្រជាជនអញ្ចឹងបានថាគេធ្វើអីនេះ ណាស់ ។

ដារ៉ា: ខ្ញុំធ្លាប់ទៅកន្លែងអាងត្រពាំងថ្មដំបូងណាពូ អាយើងជិះទៅវាមានឃើញដូចរូបនាគ?

សេង: អាហ្នឹងស្ពាន ។

ដារ៉ា: អាហ្នឹងជាស្ពានពីបូរុមបូរាណ?

សេង: បាទ! ស្ពានចាស់ ។

ដារ៉ា: អាហ្នឹងជាក្បាលឬក៏យ៉ាងម៉េចកន្លែងហ្នឹង?

សេង: អាកន្លែងហ្នឹងគិតទៅវាថ្មបាយក្រៀម ។

ដារ៉ា: បាទ! ថ្មបាយក្រៀម ។

សេង: អាហ្នឹងយូហើយ តាំងពីបូរុមបូរាណមក ។

ដារ៉ា: ហ្នឹងហើយខ្ញុំដឹងថាពីបូរុមបូរាណមក តែចង់និយាយថាបើយើងគិតពីអាងត្រពាំងថ្មអាហ្នឹងជាចំនុចដើមគេហើយទៅរហូតហ្នងឬក៏យ៉ាងម៉េច?

សេង: ពេលហ្នឹងគេចាប់ផ្ដើមធ្វើអាហ្នឹងសិនទេ ធ្វើអាស្ពានទី១មកលិច រួចហើយបានគេចាប់ផ្ដើមអាស្ពានទី១មកភូមិ ។

ដាតា: អញ្ចឹងបានន័យថាកន្លែងចាប់ផ្ដើមគឺស្ពានទី១?

សេង៖ បាទ! គឺស្ពានទី១មកពន្លៃ ធ្វើស្ពានទី១មកពន្លៃរួចហើយបានគេចាប់ផ្ដើមធ្វើពីស្ពានទី១មក កាន់ភូមិត្រពាំងថ្ម ចំងាយប្រហែលជា៦០០-៧០០ម៉ែត្រពីស្ពានទី១មក ។

ដារ៉ា៖ ស្ពានទី១មកត្រពាំងថ្មអាហ្នឹងមកទិសខាងអីពូ?

សេង៖ ទិសខាងកើត ។

ដារ៉ា៖ អាហ្នឹងខាងកើត?

សេង៖ បាទ!

ដារ៉ា៖ អញ្ចឹងពេលដែលមកដល់ត្រពាំងថ្មដំបូងហ្នឹងគឺចាប់សង់ពីស្ពានទី១ទៅ?

សេង៖ បាទ! ពីស្ពានទី១ទៅលិច ។

ដារ៉ា៖ អាហ្នឹងកងពូនៅដដែលទេដែលមកលើកហ្នឹង?

សេង៖ បាទ!

ដារ៉ា៖ មានកងផ្សេងៗមកលើកទេពូ?

សេង៖ មាន! មានរហូតទៅដល់៣វរៈសេនាតូច ។

ដារ៉ា៖ ៣វរៈសេនាតូច?

សេង៖ បាទ!

ដារ៉ា៖ អញ្ចឹងមកដល់កន្លែងស្ពានទី១ហ្នឹង គឺការកសាងទំនប់ហ្នឹងគឺមានគំនិតផ្ដួចផ្ដើមពីអ្នកណាមក ឬក៏មានផែនការមានប្លង់អីយ៉ាងម៉េច?

សេង៖ ពេលហ្នឹងមកដល់ភ្លាមគឺឈ្មោះ វ៉ាល់ តាវ៉ាល់ ហ្នឹងហៅប្រធានវរៈសេនាតូចទាំង៣ហ្នឹងទៅ ប្រជុំ ដល់ពេលទៅប្រជុំមិនដឹងប្រជុំរឿងអីយើងអត់ដឹងទេណា៎ រួចដល់វរៈសេនាតូចមកវិញ ក៏ហៅប្រធានកងធំប្រជុំ ប្រជុំហើយក៏ចាប់វាស់ដីចែកគ្នា វរៈសេនាតូចទី១ត្រូវទទួលដី ប៉ុណ្ណេះម៉ែត្រ ឧទាហរណ៍ថា ៣០០ម៉ែត្រគឺវរៈសេនាតូច អាហ្នឹងវរៈសេនាតូចលេខ១ វរៈសេនាតូចលេខ២អញ្ចេះ ហើយវរៈសេនាតូចលេខ៣អញ្ចេះ ។

ដារ៉ា៖ បន្តគ្នា?

សេង៖ បាទ! បន្តគ្នា ដូច្នេះវរៈសេនាតូចបែងចែកឲ្យកងអនុសេនាធំ អេ៎!មិត្តសេង អាហ្នឹងគេហៅ ខ្ញុំ មិត្តឯងកងអនុសេនាធំលេខ១ មិត្តឯងទទួលដីប៉ុណ្ណេះម៉ែត្រ ហើយអត់មានអីទេមានតែ ចប ។

ដារ៉ា៖ ចបហ្នឹងមានបង្គីរអត់?

សេង៖ មាន! ក៏ប៉ុន្តែកាប់ព្រៃណា៎ កាប់ព្រៃគឺខ្វែវ ។

ដារ៉ា: អត់មានប្រើចបទេ?

សេង: ប្រើចប ។

ដារ៉ា: អត់មានខ្វែវទេ?

សេង: មាន ខ្វែវវាមានតែមាន៣-៤-៥ ធ្វើអីបើកម្លាំង១០០ ៨០នាក់ហើយហ្នឹង ។

ដារ៉ា: អញ្ចឹងដំបូងយើងកាប់ព្រៃទេ?

សេង: កាប់ព្រៃ ។

ដារ៉ា: កាប់ព្រៃ?

សេង: បាទ! កាប់ព្រៃហើយរុករើដុតឲ្យស្អាតហើយបានចាប់ផ្ដើមយើង ។

ជាតា: ហើយពេលកាប់ដីដំបូងហ្នឹងចែកម្នាក់ប៉ុន្មានម៉ែត្រ?

សេង: មុនដំបូងទៅអញ្ចេះវាអត់ចំនេញ កាប់រួមដាក់យើងវាយកម្លាំងទៅអញ្ចេះអត់ចំនេញហើយ គេចាប់ផ្ដើមចេញម្នាក់២ម៉ែត្រ ទទឹង២ម៉ែត្រ ឡើងលីប៉ាប់មកវាស់២ម៉ែត្រទៅដល់ហើយ មិនដឹងម៉ែត្រណាណើម្នាក់ពីជំហានៗ ឧបមាថាយើងកម្លាំងឈឺផងអីផងវាមិនដល់១០០ ប៉ុន្តែគេនៅតែគិតយើង១០០ យើងនៅសល់៨០នាក់ឬនៅសល់៩០ក៏គេគិតឲ្យយើង ១០០ គិតទាំងអស់ ។

ដារ៉ា: យើងគិតអញ្ចឹងគឺសម្រាប់របបអាហារឬក៏យ៉ាងម៉េច?

សេង: អត់ទេ គិតរបបធ្វើការ ។

ជាតា: អញ្ចឹងពេលចូលភ្ជួមហ្នឹង អាហារគេអត់ទាន់បែងចែកតាម?

ដារ៉ា: អញ្ចឹងគេវាស់ចែកអញ្ចឹងតូ វាស់ចែក២ម៉ែត្រៗ?

សេង: បាទ!

ដារ៉ា: អញ្ចឹងមុនដំបូងកាប់ព្រៃទេ ដល់ពេលហ្នឹងយើងត្រូវវាស់កាប់ផ្ការព្រៃសិន មិនទាន់បានជាលើកជាអីទេ?

សេង: បាទ! នៅទេ ។

ដារ៉ា: កាប់ប៉ុន្មានខែ?

សេង: មិនយូទេកាប់ ដល់ពេលវាយទៅវាយតែពីរដងជិតទៅដល់មុខស្ពានទី១ដល់ស្ពានទី២ ហើយដល់ពេលអញ្ចឹងទៅគេកំណត់ថាក្នុងម្នាក់គឺ២ជំហានបានន័យថា២ម៉ែត្រ ពីនេះមកនេះកាត់ទទឹងអញ្ចេះ បើអ្នកណាបាន២ម៉ែត្រឡើងហូបបាយចុះ អ្នកណាមិនទាន់បានគឺត្រូវតែកាប់ឲ្យរួចក្នុងមួយថ្ងៃ ។

ដារ៉ា: ក្នុងមួយថ្ងៃ?

សេង: បាទ!

ដារ៉ា: អញ្ចឹងកាប់ព្រៃហើយបានយើងត្រូវលើកដី?

សេង: បាទ!

ដារ៉ា: អញ្ចឹងការកាប់ព្រៃហ្នឹងប្រហែលជារយៈពេលប៉ុន្មានបានហើយ?

សេង: រយៈប្រហែលជាមិនយូប៉ុន្មានទេ ប្រហែលជាខ្ទង់កន្លះខែជាងហ្នឹង ។

ដារ៉ា: អញ្ចឹងទេ?

សេង: បាទ! អាហ្នឹងចាប់ពីស្ពានទី១ ស្ពានទី២ ដំណាក់កាលទី១ស្ពានទី២មកស្ពានទី៣អាហ្នឹងក្រោយទៀត ។

ដារ៉ា: អញ្ចឹងពេលដែលពួមកដល់ដំបូងហ្នឹង កន្លែងអាងត្រពាំងថ្មត្រពាំងអីហ្នឹងគឺអត់ទាន់មានអាងអត់ទាន់មានទំនប់អីទេ?

សេង: អត់ទេ វាមានដីទួល ផ្លូវទួលចាស់បុរាណតាំងពីដើមមក ផ្លូវហ្នឹងផ្លូវចាស់បុរាណពីដើមមក ។

ដារ៉ា: អញ្ចឹងពេលដែលចាប់ផ្ដើមធ្វើអាងត្រពាំងថ្មហ្នឹង គឺថាបានផែនការពីណា អ្នកណាជាពូអាចដឹងទេថាអ្នកណាគំនិតផ្ដួចផ្ដើមដំបូងថាត្រូវតែលើកអាងកន្លែងហ្នឹងធ្វើទំនប់?

សេង: បើគិតទៅ បើ តាខូវ ហើយ តាវ៉ន ប្រធានវរៈសេនាតូចទទួលពី តាវ៉ាល់ ដល់ពេលតាវ៉ាល់ គាត់និយាយពេលប្រជុំគាត់ថាអង្គការ មិនដឹងអ្នកណាជាអង្គការ មិនដឹងឈ្មោះអីគាត់មិនបានបង្ហាញឈ្មោះថាឈ្មោះ«កខ»អីទេណា៎ បានបង្ហាញថាឈ្មោះ តាញឹម ប៉ុក៏ឈ្មោះ មូល សម្បត្តិ ហ្នឹងប្រធានភូមិភាគឲ្យធ្វើក៏គាត់មិនបានថា គាត់ថាអង្គការឲ្យធ្វើតែមិនដឹងអង្គការឈ្មោះអី អត់ដឹងដែរ ។

ដារ៉ា: ចុះពេលដែលប្រធានវរៈសេនាតូចរបស់ពូទៅប្រជុំជាមួយ តាវ៉ាល់ ហ្នឹងគាត់មានបាននិយាយថាតើការមកធ្វើទំនប់ហ្នឹងវាមានជាផែនទី ជាប្លង់អីត្រឹមត្រូវទេមកលើកហ្នឹង?

សេង: បើគិតទៅ តាវ៉ាល់ ជាមនុស្សដែលខ្ញុំបានជិតដិតហ្នឹងគាត់ដែរ ផ្ទះគាត់ពិតប្រាកដគឺនៅជប់នៅជិតមាត់ស្រះខាងកើតណា៎ គាត់នៅហ្នឹង ហើយគាត់ថាអង្គការតែខ្ញុំមិនដឹងថាអ្នកណាទេគាត់ជាអ្នកគូសប្លង់ ហើយពេលនោះគាត់ផឹកស្រាដែរណា៎ ស្រាកាលសម័យយើងវាមានអត់ស្រាណា៎ សំបូរអាពួកស្រាខ្មៅ ស្រាសាច់ជ្រូ ប៊ិច៤-៥ហើយក្រដាសរ៉ាមធំៗមកគូសហើយអាណាដែលមិនត្រូវគាត់បោះចោល ហែកចោល ។

ដារ៉ា: អញ្ចឹង?

សេង៖ បាទ! ហែកចោល បោះចោល ។

ដារ៉ា៖ ពូឃើញផ្ទាល់ភ្នែកហ្មង?

សេង៖ បាទ! អាហ្នឹងឃើញផ្ទាល់ភ្នែក ព្រោះខ្ញុំហើយនឹងគាត់ធ្លាប់ត្រូវគ្នា បានត្រូវជាមួយគាត់ ។

ដារ៉ា៖ អញ្ចឹងបានន័យថាលើកត្រពាំងថ្មហ្នឹងគឺមានគូសប្លង់មានអីត្រឹមត្រូវ តែគ្រាន់ថាប្លង់ហ្នឹងពូមិនដឹងមកពីណា ហើយគ្រាន់ឃើញ តាវ៉ាល់ គាត់គូស?

សេង៖ តាវ៉ាល់ អ្នកគូស ។

ដារ៉ា៖ គាត់ចេះបូកដាក់លេខអីយ៉ាងម៉េចពូ?

សេង៖ ទេ បើគិតទៅមនុស្ស តាវ៉ាល់ មិនមែនជាមនុស្សល្ងង់ទេ មនុស្សបែបជាមនុស្សគ្រាន់បើ ចំណេះដឹងបែបរៀនបានខ្ពស់ដែរ អក្សរគាត់សរសេរគាត់មិនដែលឲ្យផ្ទាល់ដៃទេ មិនដែលដល់ក្រដាសទេ សរសេរឃ្លាកក៏ប៉ុន្តែដាក់តែអញ្ចឹង បើសរសេរមកខ្ញុំ “សមមិត្ត សេង ជាទីស្នេហាបំផុត” ហើយប៉ុណ្ណឹងសរសេរតែ៣-៤ប៉ុណ្ណឹងទេ ។

ដារ៉ា៖ សរសេរតែ៣-៤បន្ទាត់ទេ?

សេង៖ បាទ! ហើយយើងឃើញការសរសេររបស់គាត់ហើយនឹងគំនិតរបស់គាត់ ប៉ុន្តែទាស់មួយគឺសម្លាប់មនុស្ស ប៉ុន្តែបើចំណេះដឹងគឺមនុស្សហ្នឹងមនុស្សចេះ ។

ដារ៉ា៖ អញ្ចឹងពូនិយាយដល់រឿងការសម្លាប់ ដូចថារាល់ការសម្រេចថាសម្លាប់ថាអីហ្នឹងគឺចេញពីតាវ៉ាល់ ដែរឬក៏យ៉ាងម៉េច?

សេង៖ ទេ មានមួយចំនួនគឺចេញពីគាត់ដែរ តែមានមួយចំនួនទៀតគឺតែគ្នាឯងហ្នឹង ចាប់ពីលំដាប់ប្រធានកងធំក៏អាចសម្លាប់មនុស្សបានដែរ ឲ្យតែអ្នកណាដែលមិនពេញចិត្ត ។

ដារ៉ា៖ អត់មានចាំបាច់ឆ្លងមកអ្នកណាទេ?

សេង៖ កម្រណាស់ ។

ដាតា៖ អង្គការគេមានប្រាប់ទេថា មិត្តឯងមានសិទ្ធធ្វើនេះៗ គេដែលនិយាយទេពូ?

សេង៖ ទេ គេចង់និយាយឲ្យខ្ញុំទៅ ប្រជុំប្រធានកងយើងគេប្រាប់ថាអ្នកណាដែលប្រឆាំងហ្នឹងអង្គការ អ្នកនោះគឺត្រូវតែស្លាប់ ។

ដាតា៖ អញ្ចឹងពេលប្រជុំហ្នឹងមានអ្នកណាគេខ្លះដែលគេហៅទៅ ហើយគេនិយាយអញ្ចឹង?

សេង៖ អាហ្នឹងពេលប្រជុំគឺមានតែប្រធានកងទេ ហៅប្រធានកងទៅប្រជុំ អ្នកណាដែលប្រឆាំងហ្នឹងអង្គការអ្នកនោះត្រូវស្លាប់ ។

ដារ៉ា: អញ្ចឹងពេលដែលដូចថាមានការសម្លាប់មនុស្សនៅក្នុងកងក្នុងអីអញ្ចឹង ដែលពូថាប្រធានកង ក៏អាចមានសិទ្ធសម្លាប់ដែរអញ្ចឹងណា៎ អញ្ចឹងវាអាចថាបាត់សមាជិកនៅក្នុងកងមិនអញ្ចឹង?

សេង: បាទ!

ដារ៉ា: ហើយចុះបើបាត់អញ្ចឹង គឺថាវរៈសេនាតូចឡើងមក ហើយ តាវ៉ាល់ តាអីមានសួរយើងថា ហេតុអីបានបាត់សមាជិកហ្នឹងទេពូ?

សេង: ទេ អត់មានសួរផង ប៉ុន្តែខបមាថាបើយើងណាមួយឲ្យតែទើសហ្នឹងប្រធានកង ហើយ ប្រធានកងវាអត់មានចិត្តមេត្តាទេណា៎ អាហ្នឹងគឺយកទៅវ៉ៃចោលហើយ ហើយយកទៅវ៉ៃ ចោលបើថាយ៉ាងណាទៅគឺប្រាប់វរៈ ព្រឹកឡើងគឺប្រធានវរៈប្រាប់ថា បងអើយ! អានោះ ខ្ញុំកំចាត់ចោលហើយ អាហ្នឹងវាតថ្លៃ ឲ្យវាធ្វើនេះវាមិនធ្វើ វាថាវែកមិនមែនដីម៉ែអញ បាយស៊ីមិនឆ្អែត ការពិតគ្នាមិនបានថាអីទេថាប៉ុណ្ណឹងទៅរួចខ្លួនហើយ ។

ដារ៉ា: អត់មានថាគេដាក់កំហុសអីអ្នកសម្លាប់មេកងហ្នឹងទេ?

សេង: អត់ទេ ។

ដារ៉ា: អញ្ចឹងពេលដែលមកធ្វើអាងត្រពាំងថ្មហ្នឹង គឺថាពូបានឃើញផ្ទាល់ភ្នែកថា តាវ៉ាល់ គាត់គួស វាសអញ្ចឹងហ្នង?

សេង: បាទ! គឺ តាវ៉ាល់ គាត់គួសវាសមែន ។

ដារ៉ា: គួសវាស អញ្ចឹងដល់ពេលដែលលើកហ្នឹងពូអាចសន្និដ្ឋានបានទេថា ពេលដែលលើកត្រពាំងថ្ម ហ្នឹងទៅវាចេញទៅតាមអ៊ីដែល តាវ៉ាល់ គាត់គួសវាសហ្នឹងដូចគ្នាហ្នឹងការគូសហ្នឹងឯង?

សេង: តាមដែលខ្ញុំមើលទៅតាមដែនទីហ្នឹងគឺដូច ។

ដារ៉ា: ដូចហ្នង?

សេង: បាទ! ដូច ប៉ុន្តែកាលដែលគាត់ធ្វើស្ពាន គូសស្ពានដូចជាធំដល់ពេលធ្វើដូចជារាងតូច ។

ដារ៉ា: អញ្ចឹងមានន័យថា អាងត្រពាំងថ្មហ្នឹងគឺអាចថាជា តាវ៉ាល់ អ្នកធ្វើអ្នកគូសប្លង់គូសអីណា ពូ?

សេង: បាទ! គាត់អ្នកគូស ។

ដារ៉ា: តាមដំបូងហ្នឹងគឺថា អាប្លង់ត្រពាំងថ្មហ្នឹងលើកជាទំនប់ហ្នឹងគឺថា ខ្នងទំនប់ប៉ុន្មាន ហើយទទឹង ប៉ុន្មាន ហើយកំពស់ប៉ុន្មាន ហើយបាតក្រោមប៉ុន្មានទៅ ពេលដែលដែនការឲ្យលើកចេញពី ប្លង់?

សេង: ពេលហ្នឹងដាក់ផែនការមកឲ្យខ្ញុំជាប្រធានកងនេះ ខ្ពង់លើគឺ២៥ម៉ែត្រ កំពស់ដីទួលគឺ៣ម៉ែត្រ ដីទំនាបដីដែលមានត្រពាំងមានអីអាហ្នឹងធ្វើម៉េចឲ្យកំពស់ប៉ុន្មានក៏ដោយឲ្យតែវារត់ភ្ជាហ្នឹង៣ម៉ែត្រហ្នឹង ។

ដារ៉ា: ជាទូទៅបើជាកន្លែងទំនាបឬក៏កន្លែងត្រពាំងអញ្ចឹង ប្រហែលជាកំពស់ប៉ុន្មានបានអាចស្មើរគ្នាហ្នឹងអាខ្ពង់?

សេង: បាទ! វាមាន៤ក៏មានហើយ៥ក៏មានដែរ ។

ដារ៉ា: អញ្ចឹង?

សេង: បាទ!

ដារ៉ា: បើនិយាយជាមធ្យមភាគ បើសិនជាយើងយកមធ្យមភាគវិញថាបើខ្ពស់បំផុតប៉ុន្មាន កន្លែងទំនាបកន្លែងអីហ្នឹង?

សេង: កន្លែងទំនាបដូចស្ពានរាបៗនោះ បើសិនជាកំពស់ចូល៦ហើយ ។

ដារ៉ា: ចូល៦?

សេង: បាទ!

ដារ៉ា: ហើយកន្លែងស្ពានរាបហ្នឹងចូល៦?

សេង: ចូល៦ តែវាខ្លីដែរ ចូល២០០ម៉ែត្រហ្នឹងវាខ្លីដែរ ។

ដារ៉ា: ហើយមធ្យមកន្លែងដែលទាបសម្រាប់ទំនាបហ្នឹងប៉ុន្មាន?

សេង: អាទាបមធ្យមយើងថាប្រហែលជាវាចូល៣កន្លះឬក៏៤អីហ្នឹង ។

ដារ៉ា: អាហ្នឹងភាគច្រើនឬក៏ភាគតិច?

សេង: អាហ្នឹងចូលភាគច្រើនហើយ បើ៣ហ្នឹងភាគតិចទេ បើអាចាប់ពី៤ទៅដល់៥ហ្នឹងអាហ្នឹងច្រើន ។

ដារ៉ា: វាវែង?

សេង: បាទ! វាវែង ។

ដារ៉ា: អញ្ចឹងខ្ពង់ទំនប់២៥ម៉ែត្រ?

សេង: បាទ!

ដារ៉ា: ចុះបាត?

សេង: បាតកំណត់៤០ម៉ែត្រ ។

ដារ៉ា: អាហ្នឹងជាផែនការដំបូងដែលពូទទួលមកឲ្យលើកហ្នឹង?

សេង៖ បាទ! ទទួលពីប្រធានវរៈសេនាតូច ។

ដារ៉ា៖ អញ្ចឹងក្នុងហ្នឹងគេមានកងត្រូវលើក គេមានកងត្រូវកាប់ដី កងរែកដី ឬកងពង្រាបខ្នងទំនប់អីខុសៗគ្នាដែរឬក៏យ៉ាងម៉េចពូ?

សេង៖ ពេលហ្នឹងម្នាក់គឺឲ្យយើងទទួលខុសត្រូវគឺ ដងរែក១ បង្គីរ២ ហើយនឹងចប១ ហើយគេវាស់ ឲ្យយើងទៅ ហើយអ្នកដែលត្រូវពង្រាបដីហ្នឹងគឺប្រធានកង ហើយអ្នកដែលជាអ្នកល្វិត អ្នក ភ្នែកពិការ ម្តូប ឬក៏ក្នាឈឺដើងឈឺអីនាយអាយ នៅអាចប្រើការជាផ្លូវការបានគេមានឈើមួយកំណាត់អន្តុយដុំតែខ្នងហ្នឹងទៅ ឬក៏ចបមួយពង្រាយអញ្ចេះអញ្ចុះទៅ ។

ដារ៉ា៖ អញ្ចឹងអ្នកដែលលើកហ្នឹងគឺកាប់ដីសែងឡើងហ្នឹងគឺមានតែកាប់ដីសែងឡើងចាក់ហ្មង?

សេង៖ បាទ!

ដារ៉ា៖ អ្នកពង្រាយហ្នឹងផ្សេងទេ?

សេង៖ បាទ!

ដារ៉ា៖ ចុះទាក់ទងនិងស្ពានហ្នឹង ស្ពាន ហ្នឹង តាវ៉ាល់ គាត់អ្នកគូសដែរឬក៏ម៉េចពូ?

សេង៖ ឃើញគាត់គូស គូសទាំងអស់ គូសពីពីចន្លោះមួយទៅចន្លោះមួយប្រហែលជាប៉ុន្មាន ដូចថាពគីឡូអីទៅត្រូវដាក់ស្ពានមួយ វាមានអេះវាណា៎ ដល់ឃើញគេនេះខ្ញុំសួរគេថាអានេះចន្លោះគេថាអាហ្នឹងធ្វើស្ពាន ធ្វើស្ពានធ្វើអីៗ ។

ដារ៉ា៖ ហើយស្ពានហ្នឹងពូនិយាយពីខាងដើម អ្នកណាដែលជួយធ្វើស្ពានហ្នឹង?

សេង៖ ពេលហ្នឹងគឺគាត់ស្រាវជ្រាវ ប្រាប់ប្រធានកងឲ្យស្រាវជ្រាវរកវិស្វករណាដែលចេះធ្វើស្ពានអ្នកមកពីភ្នំពេញគេមិនអត់ទេ គេចេះ ។

ដារ៉ា៖ គាត់និយាយអញ្ចឹង ។

សេង៖ បាទ! គាត់និយាយអញ្ចឹង ម៉េចមិត្ត សេង មិត្តឯងមានទេ ហើយខ្ញុំថា អ៎! បងខ្ញុំមិនដែលបានសួរផង កងខ្ញុំប្រហែលជាមិនមានទេ សុទ្ធតែអ្នកល្ងង់ សូម្បីតែអ្នកទាហានក៏វាមិនមានផង អ្នកចេះក៏មិនមាន មិនមានទេបង ឯងស្រាវជ្រាវមើលទៅ មិនដឹងស្រាវជ្រាវណាទេហ៊ានតមាត់បន្តិចបន្តួចដែរហ្នឹង ដល់ក្រោយមកគាត់ប្រជុំមិនដឹងបានពីកងណាឈ្មោះ តាទេន តាហ្នឹងគាត់ខ្ពស់ហើយជ្រះ គាត់ខ្ទមូល កំពស់គាត់ប្រហែលជាខ្ពង់១ម៉ែត្រ៦០លើស ប្រហែលជា១ម៉ែត្រ៦៧-៦៨ គាត់ចេះ ទៅដល់គាត់ហៅ មិត្តឯងធ្លាប់ធ្វើទេ គាត់ខ្ញុំធ្លាប់ធ្វើពីសង្គម ធ្វើស្ពានធ្វើលូអីខ្ញុំចេះ គាត់ប្រាប់ថាចេះ

ហើយគាត់ប្រាប់ហ្នឹងថាបើទទឹងប៉ុណ្ណេះ បណ្ដោយប៉ុណ្ណេះ ទំហំប៉ុណ្ណេះអស់ស៊ីម៉ង់ប៉ុន្មាន ដែកប៉ុន្មាន អស់លួសប៉ុន្មាន អញ្ចឹងទៅគាត់ សុំប៊ិចសុំក្រដាស តាវ៉ាល់ យកប៊ិចយកក្រដាសមកគាត់ប្រាប់ ទទឹងគឺប៉ុណ្ណេះ បណ្ដោយគឺ ប៉ុណ្ណេះ ប៉ុន្តែខ្ញុំភ្លេចហើយណា៎ ដល់ក្រោយមកបានគាត់ប្រាប់វិញថា គាត់ប្រាប់ថាអាដែក តូចយើង៦លីអស់ប៉ុណ្ណេះ ហើយអាធំអស់ប៉ុណ្ណេះ លួសអស់ប៉ុណ្ណេះគីឡូ ហើយខ្សាច់និង ស៊ីម៉ង់ចុះបង់ឯង គាត់ហៅបង់ឯង ចុះបង់ឯងលាយម៉េច ក្នុងខ្សាច់មួយគីបបង់ឯងដាក់ ស៊ីម៉ង់ប៉ុន្មានការ៉ុង ប៉ុន្មានកញ្ចប់ គាត់និយាយកញ្ចប់ បានន័យថាក្នុងកន្លះម៉ែត្រគីបដាក់៣ កញ្ចប់ អញ្ចឹងគិតទៅស៊ីម៉ង់ត្រូវអស់ប៉ុណ្ណេះតោន ខ្សាច់ត្រូវអស់ប៉ុណ្ណេះ ហើយដែកត្រូវ អស់ប៉ុណ្ណេះអា៦លី អា១០លី អាធំអស់ប៉ុណ្ណេះៗ ដល់គាត់ថាអញ្ចឹងទៅ តាវ៉ាល់ គាត់ ចុះមកធ្វើរួចចាប់ផ្ដើមហើយ ចាប់ផ្ដើមដកកម្លាំងមកជីក ជីកទម្ងុះអាទំនប់ចាស់ អាផ្លូវចាស់ ជីកទំហំប៉ុណ្ណេះ គិតទៅគ្រឹះហ្នឹងចង់ចូលលិចក្បាលខ្ញុំបាត់ គ្រឹះ២ម៉ែត្រ ជីកគ្រឹះទៅក្រោម ដាក់ទៅក្រោមនៅហ្នឹងថ្ម រកអាគ្រាក់ទ័រដាក់។

ដារ៉ា: ថ្មហ្នឹងយកមកពីណា?

សេង: ជីកពីភ្នំពន្លៃ ភ្នំតាគ្រៀម។

ដារ៉ា: មានគ្រឿងចក្រអីធ្វើដែរកាលហ្នឹង?

សេង: ត្រាក់ទ័រ មាននៅជីកត្រាក់ទ័រ ហើយកម្លាំងលោក ឃ្វី សព្វថ្ងៃគេប្រធានឃុំនៅស្រុកបាវី បើឈ្មោះហ្នឹងហៅ ឃ្វី តែដល់ក្រោយគេហៅ ខាន់ ចំរើន ប្រធានឃុំស្រុកបាវី អាហ្នឹង កម្លាំងគេអ្នកជញ្ជូនថ្ម កាលហ្នឹងប្រធានកងដូចខ្ញុំដែរណា៎ កំណើតគេអ្នកដូនជ្រៃ។

ដារ៉ា: អញ្ចឹងពេលដែលធ្វើស្ពានធ្វើអីគាត់ទៅរកវិស្វករ?

សេង: បាទ!

ដារ៉ា: ហើយវិស្វករដែលឈ្មោះ តាទេន ហ្នឹងអត់មានចេញពីកងពូទេ ឬក៏ចេញពីវរៈរបស់ពូ ដែរ?

សេង: ខ្ញុំក៏មិនដឹង បើវា៣០០នាក់មិនស្គាល់មិនអស់កាលនោះ ទៅភ្លាម ហើយខ្ញុំក៏មិនដឹងថាយក ពីណាពីណើមកអត់ដឹងទេ។

ដារ៉ា: អញ្ចឹងពេលដែលលើកម៉ាស្ពានទី១ហ្នឹងពូ ជួរឬក៏មុខញ្ញ្រញរបស់ពូនៅស្ពានទី១អញ្ចឹងមុន ដំបូង?

សេង: មុនដំបូងគឺត្រូវទាំងអស់ ត្រូវកាប់ព្រៃកាប់អីរួចហ្នឹងបានម៉ាមុខសញ្ញារបស់ខ្ញុំនេះត្រូវមកនៅស្ពានទី១ ។

ដារ៉ា: អញ្ចឹងពេលហ្នឹងលើកប៉ុន្មានខែប៉ុន្មានឆ្នាំ?

សេង: លើកហ្នឹងយូដែរ ក៏ប៉ុន្តែពេលនោះវាមានជាង២ណាក់ តាទេន ហ្នឹងគ្រាន់តែវាស់ឲ្យទេ គាត់អ្នកវាស់ ហើយមានតាមួយ ឈ្មោះ តាមុង ។

ដារ៉ា: និយាយថា តាទេន ហ្នឹងគាត់វាស់សម្រាប់តែធ្វើស្ពានឬក៏វាស់ខ្នងទំនប់ខ្នងអីដែរ?

សេង: ទេ គាត់វាស់តែរឿងស្ពានទេ គាត់វាស់ស្ពានវាស់អីរួចហើយ គាត់ទៅវាស់នោះទៀតមាន តាមុង មួយហ្នឹងជាអ្នកទទួលបន្ទុកពីក្រោម តាទេន ទៀតព្រោះ តាទេន ត្រូវស្ពានទី១ ស្ពានទី២ នឹងស្ពានទី៣ ហើយងាកមកធ្វើអាគេហៅស្ថានីយ៍បូមទឹកនៅចាបគោកទៀម ទៀតគាត់គ្រាន់តែវាស់ឲ្យហើយដូចមេជាងណា វាស់រួចហើយប្រគល់ឲ្យ តាមុង ហ្នឹងជាអ្នកធ្វើទទួលខុសត្រូវ ។

ដារ៉ា: ឈ្មោះ មុង?

សេង: ឈ្មោះជាង មុង ។

ដារ៉ា: ហ្នឹងគាត់ជាអ្នកអនុវត្តផ្ទាល់?

សេង: គាត់អ្នកប្រចាំការ ។

ដារ៉ា: ប្រចាំការ?

សេង: បាទ!

ដារ៉ា: តាមុង ហ្នឹងអ្នកមកពីណា?

សេង: តាមុង កំណើតយើងពួកភូមិភាគហ្នឹងឯង ពួកពាយ័ព្យហ្នឹងឯង តែមិនដឹងជាកំណើតគាត់នៅណា គាត់ចាស់ដែរហើយ មិនមែនពួកនារតីទេ ពេលនោះនារតីមិនទាន់មកដល់ទេ ។

ដារ៉ា: អញ្ចឹង តាមុង ហ្នឹងនៅក្នុងកន្លែងណាអីកន្លែងណាដែលរើសបាន?

សេង: ទេ ពេលនោះខ្ញុំអ្នកដឹក ខ្ញុំអ្នកអីអញ្ចឹងទៅស្រាប់តែឃើញជាងគេមក ជាងគេមកឃើញ តាមុង ហ្នឹងឯង ហើយ តាទេន មកវាស់មកអីប្រាប់នាយអាយរួច តាទេន ជិះកង់ចិនមួយអាកង់ខ្មៅទៅដុតទៅប្រាប់ តាមុង ថាជាងឯងធ្វើអញ្ចេះៗ ហើយខ្ញុំស្រាប់តែធ្វើតាមទៅ បានចាក់ដែរ ចងដែក វែកទឹកមកចាក់ ហើយពេលនោះទឹកវាអត់មកវែកស្រះប៉ោយចាយត្រពាំងថ្ម១០០នាក់ណាក់ ។

ដារ៉ា: គ្រាន់តែវែកទឹកហ្នឹង?

សេង ៖ បាទ!១០០នាក់ កាចាំងវាអត់គ្រប់១០០ទេៗ ប៉ុនកាចាំងវាអត់គ្រប់១០០ទេ សុំសហករណ៍គេសុំបាន៩០ទៅ អាប៉ុន្មានវែកនេះដូចថាឈ្មោះ“ក”អញ្ចឹងទៅអានេះយកមកដាក់ទៅ អា“ខ”ទៅម្ដងទៅ ។

ដារ៉ា ៖ អញ្ចឹងមុនដំបូងពូថាបានលើកខ្នងទំនប់ហ្នឹង លើកហើយ?

សេង ៖ អត់ទាន់ហើយទេ ទោះកាលណាអ្នកលើកគឺនៅតែលើកអាអ្នកធ្វើស្ពានគឺធ្វើ ។

ដារ៉ា ៖ អញ្ចឹងពូនិយាយមិញថាពូបានម៉ោវែកទឹកលាយស៊ីម៉ង់ដែរ?

សេង ៖ បាទ!ពេលនោះគេដកកងខ្ញុំ គេដកមាំកងខ្ញុំហ្នឹងម៉ោយក១០០នាក់ម៉ោ យកមកឲ្យការងារស្ពាន ។

ដារ៉ា ៖ ការងារស្ពានវិញ?

សេង ៖ បាទ!ការងារស្ពានវិញ ហើយអា២០០នាក់នោះគេវែកដី ព្រោះក្នុងមាំវរៈសេនាតូចវាមាន៣កងធំ ដកអាមាំកងខ្ញុំឲ្យមកធ្វើស្ពាន ហើយអា២កងហ្នឹងគេវែកដី ។

ដារ៉ា ៖ អញ្ចឹងមាំជំនាន់តាវ៉ាល់គេធ្វើទំនប់ហ្នឹង មានតែវរៈសេនាតូចប៉ុន្មានហ្នឹងទេ ឬក៏មានប្រជាជនអីម៉ោជួយលើកទំនប់ហ្នឹងដែរពូ?

សេង ៖ ពេលហ្នឹងគឺចល័តរបស់ តាវ៉ាល់គឺមាន៣វរៈសេនាតូច វរៈសេនាតូចទី១ វរៈសេនាតូចទី២ វរៈសេនាតូចទី៣ ក៏ប៉ុន្តែបើមិនគ្រប់ទៅនឹងដកតាំងពីគេហៅថាចល័តសហ ករណ៍ម៉ោពីស្រុកថ្មពួក បាទ!ពេលហ្នឹងស្រុកស្វាយចេកយើងអត់ទាន់មានទេៗស្រុកទេ គឺមានតែស្រុកថ្មពួកតែមួយទេ ហើយដូចយើងដូចជាខេត្តបាត់ដំបង កាលហ្នឹងយើង មិនទាន់កើតខេត្តបន្ទាយមានជ័យទេ ដកតាំងពីស្រុកថ្មពួក ដកស្រុកព្រះនេត្រព្រះដក ម៉ោទាំងអស់ហៅចល័តសហករណ៍ យកទៅជួយនឹងឯង ជួយចល័តតំបន់ ។

ដារ៉ា ៖ បាទ!អញ្ចឹងជួយហ្នឹងគឺក្នុងចំនួនមនុស្សប៉ុន្មានទៅពូ?

សេង ៖ គិតទៅច្រើនដែរ គិតទៅវាមាំខែ្សត្រៀមពីស្ពានទី១ទៅ រហូតដល់ទៅស្ពានទី២នោះវា៣គីឡូជាង ២ខ្សែត្រៀមដើរម៉ោស្ពានទី៣ ។

ដារ៉ា ៖ អញ្ចឹងមនុស្សបើពូគិតជាការប៉ាន់ស្មាន មានមនុស្សប៉ុន្មានដែលចូលរួមលើកមាំអាងត្រពាំងថ្មហ្នឹង ។

សេង ៖ មនុស្សចូលម៉ឺន ។

ដារ៉ា ៖ ចូលម៉ឺនពាក់?

សេង ៖ បាទ!ចូលម៉ឺនពាក់ ច្រើនណាស់ដល់យើងទៅមើលទៅយើងមើលអត់ឃើញដីទេ ឃើញសុទ្ធតែមនុស្សទាំងអស់ ។

ដារ៉ា ៖ អញ្ចឹងលើខ្នងទំនប់អីហ្នឹង?

សេង ៖ បាទ!សុទ្ធតែមនុស្សចូលវែក គេធ្វើផ្លូវ២ដីម៉ា កន្លែងណាដែលទឹក អាផ្លូវនេះយើងវែកឡើង ផ្លូវនេះយើងវែកចុះគេធ្វើដូចទ្វារចេញចូលអញ្ចឹង ។

ដារ៉ា ៖ អ្ហូ?

សេង ៖ បាទ!បើសិនជាដីគោក អានេះយើងធ្វើផ្លូវខ្លួនយើងៗទេ ក៏ប៉ុន្តែបើទឹកអានេះវែកចូលអានេះវែកចេញដូចផ្លូវយើងចេញចូលអញ្ចឹង ប៉ុនមនុស្សច្រើនណាស់ ស្លាប់ក៏ច្រើន ។

ដារ៉ា ៖ អញ្ចឹងការហូបចុកអីពេលលើកទំនប់ហ្នឹងយ៉ាងម៉េចដែរ?

សេង ៖ ដូចបានហូបឆ្អែត ។

ដារ៉ា ៖ បានហូបឆ្អែតតែសម្រាប់កងពូកងចល័តតំបន់ទេ?

សេង ៖ បាទៗ!សម្រាប់តែកងចល័តតំនប់ទេបានហូបឆ្អែត ។

ដារ៉ា ៖ អត់ខ្វះខាតទេ?

សេង ៖ មិនខ្វះទេ ព្រោះមួយថ្ងៃគេឲ្យ៤កំប៉ុងៗយើងហូបអត់អស់ទេ ។

ដារ៉ា ៖ អ្ហូ!ចុះចំពោះចល័តសហករណ៍ដែលនៅជួយហ្នឹង អាហ្នឹងការហូបចុកយ៉ាងម៉េចដែរ?

សេង ៖ អាហ្នឹងដូចជាគ្នាខ្វះខាត ព្រោះអត់មានការឧបត្ថមពីចល័តតំបន់ទេ គឺសហករណ៍ជាអ្នកដោះស្រាយ ។

ដារ៉ា ៖ អញ្ចឹងបើសហករណ៍ដោះស្រាយបានច្រើនក៏បានហូបទៅ?

សេង ៖ បាទៗ!បានហូបទៅ បើសហករណ៍ដោះស្រាយមិនទាន់ទេ គ្នាក៏ហូបបបររាវទៅ ។

ដារ៉ា ៖ អត់មានម៉ោច្រលូកច្រល់ជាមួយតំបន់បានទេ?

សេង ៖ អត់ទេៗ ។

ដារ៉ា ៖ ចុះការលើកអីអ្នកណាអ្នកគ្រប់គ្រងទៅ អ្នកដែលម៉ោសហករណ៍ដែលម៉ោ អ្ហូ!ចល័តដែលម៉ោអ្នកណាគ្រប់គ្រងអ្នកណាអីទៅពូ?

សេង ៖ ពេលហ្នឹងគេមាន គេមានប្រធានគេម្នាក់ ឧបមាថាម៉ោពីស្រុកថ្មពួកគេមានប្រធានគេម្នាក់អញ្ចឹងម៉ោ ក៏ប៉ុន្តែក្រោមការគ្រប់គ្រងរបស់តាវ៉ាល់ដែរ ។

ដារ៉ា ៖ របស់តាវ៉ាល់ដែរ?

សេង ៖ បាទៗ!

ដារ៉ា ៖ អពាឹងអ្នកណា ដូចថាទាំងអស់គ្នាក្រោមមការគ្រប់គ្រងរបស់តាវ៉ាល់ ប៉ុន្តែប្រសិនជាសហករណ៍ ចល័តសហករណ៍ម៉ោលើកកន្លែងពូអីដែរអញ្ចឹង មិនមែនតាវ៉ាល់គាត់ត្រូវមើលទាំងអស់បានណា អញ្ចឹងត្រូវមានអ្នកណាមួយត្រូវមើលបន្តនៅកន្លែងការដ្ឋានហ្នឹងផ្ទាល់ហ្មងពូហ្នឹងម៉េចដែរ?

សេង ៖ ខ្ញុំអត់ស្គាល់ទេៗ តាដែលទទួលខុសត្រូវម៉ាស្រុកថ្មពួក ឬស្រុកព្រះនេត្រព្រះអត់ស្គាល់ឈ្មោះគាត់ទេ ។

ដារ៉ា ៖ អញ្ចឹងដោយសារតែម៉ោលើកដែរម៉ោជួយអញ្ចឹង ជាកម្លាំងចល័តតំបន់អញ្ចឹងពូ គេអត់ឲ្យចាត់ទៅគ្រប់គ្រងអ្នកហ្នឹងដែរឬយ៉ាងម៉េច?

សេង ៖ អត់ទេៗ ។

ដារ៉ា ៖ ទោះបីជានៅជាមួយគ្នា នៅលើកដីជាមួយគ្នាហ្នឹងក៏ដោយ?

សេង ៖ បាទ!ពេលហ្នឹងយើងឧទាហរណ៍ថា ចល័តតំបន់រាយម៉ោដល់ស្ពានទី២ ចាប់ពីស្ពានទី២ទៅនេះគឺសហករណ៍ទាំងអស់ ។

ដារ៉ា ៖ អញ្ចឹង?

សេង ៖ បាទ!គេបែងចែកឲ្យទៅសហករណ៍ ចល័តតំបន់ម៉ោចេះវិញ សហករណ៍ទៅចេះវិញ ។

ដារ៉ា ៖ ដល់អញ្ចឹងទៅខាងសហករណ៍នេះគេគ្រប់គ្រងប៉ែកផ្សេងទៅ ហើយខាងតំបន់ប៉ែកផ្សេងទៅ?

សេង ៖ បាទ!ប៉ែកផ្សេងៗទៅ ។

ដារ៉ា ៖ អត់មានធ្វើការចូលគ្នាទេអញ្ចឹង?

សេង ៖ អត់ទេៗ ចូលគ្នាអត់បានទេ ។

ដារ៉ា ៖ ចូលគ្នាអត់បានទេ?

សេង ៖ បាទ! ។

ដារ៉ា ៖ អញ្ចឹងហើយបានមានអាចថាមានការស្លាប់អីច្រើន ប្រហែលនៅខាងសហករណ៍ពូ?

សេង ៖ អត់ទេសហករណ៍ដូចជាមុនសូវទេ មិនសូវវៃចូលទេ មិនសូវអីអញ្ចឹង ថ្ងៃមួយនោះដែលខ្ញុំឃើញដែលមិនភ្លេច អាហ្នឹងលើកពីអាកាច់កែងនេះពីស្ពានទី១ទៅភូមិមនោ វាមានគ្រូនាប់វាជ្រៅវាកាច់កែងនាវាម៉ោទៅបុកខ្ទាំងចង់បាក់ ដែនការណ៍ទាំងយប់ទាំងថ្ងៃពេលនោះកងខ្ញុំអត់សូវមានទេ អត់មានឈឺ ប៉ុនកងអាណាអីនោះក្នុងម៉ាវរៈហ្នឹងវា ១២នាក់វាល្វិតៗមាន់ល្វិតភ្នែកវា ដល់ទៅស្រាវជ្រាវទៅមើលទៅអីទៅក៏វាថា ដែនការណ៍របស់គាវ៉ាល់ឲ្យដុតភ្លើងៗភ្នកយកអុសម៉ោដុតឲ្យឆេះគ្រុសៗៗ ឆេះរួចហើយនេះចាប់ផ្ដើមរំលត់ រំលត់នេះយើងរួចៗវាកុំឲ្យវាឆេះ ឲ្យនៅតែរងើក ហើយប្រាប់ថាចាប់ដៃឲ្យជាប់ ចាប់ដៃគ្នាឲ្យជាប់ ហើយអាមុខគេហ្នឹងឈ្មោះវា អាជន។ អាជន ហ្នឹងប្រធានកង ពេលនោះវាមានកន្សែងមួយ ក្រមារយើងអានោះថាចាប់ដៃជាប់គ្នា ហើយអានោះថាជាប់ហើយក៏ឲ្យអាមួយនោះចាប់កន្សែង ហើយវាដើរដុតឲ្យចំ ភ្លើង ។

ដារ៉ា ៖ អញ្ចឹង?

សេង ៖ បាទ! ដើរដុតឲ្យចំភ្លើងដែលកំពុងឆេះហ្នឹង កំពុងក្ដៅ អានោះមកវាគេច អា១១នាក់ហ្នឹងវាគេច ដល់ពេលអាក្រោយហ្នឹងវាដើរជាន់ភ្លើង អ្ហូ!បងក្ដៅណាស់ ឈឺណាស់បង!ភ្លើងក្ដៅណាស់ៗរស់អាមួយក្រោយគេ ។

ដារ៉ា ៖ ចុះអាមុខហ្នឹង?

សេង ៖ អាមុខ១១នាក់ហ្នឹង នឹងទំនប់ហ្នឹងឯង ។

ដារ៉ា ៖ ហេតុអីបានធ្វើអញ្ចឹង មានហេតុផលអី?

សេង ៖ ខ្ញុំដូចពិបាកស្មានដែល វាថាយើងនឹងវាឈឺសតិអារម្មណ៍ យើងមិនមែនងងឹតទេ បើងងឹតវាដើរជាន់ភ្លើងហើយ ។

ដារ៉ា ៖ អ្ហូ!ចង់និយាយអញ្ចឹង?

សេង ៖ បាទ!គេចង់និយាយអញ្ចឹងឯង អាហ្នឹងវាខ្ជិលឈឺសតិអារម្មណ៍ ។

ដារ៉ា ៖ ដោយសារងងឹតខ្វាក់មាន់ហ្នឹងក៏?

សេង ៖ បាទ!ក៏វៃចោលដែល ។

ដារ៉ា ៖ ដឹកអញ្ចឹងដែរ?

សេង ៖ បាទ! គេសាកល្បងមើល ។

ដារ៉ា ៖ សាកល្បងដើរជាន់ភ្លើង ជាន់ភ្លើងមែនពូ?

សេង ៖ ជាន់តែអាមួយក្រោយ អាក្រោយនោះដើរជាន់មែន ប៉ុនអា ១ ១ នាក់នៅមុខវាអត់ជាន់វាគេច ។

ដារ៉ា ៖ អ្ហូ! ចង់និយាយថាអា ១ ១ នាក់ខាងមុខនោះវាដើរគេចភ្លើង?

សេង ៖ ដើរគេចភ្លើង ។

ដារ៉ា ៖ ហើយអាមួយចុងក្រោយនោះវាត្រូវដើរជាន់ភ្លើង?

សេង ៖ ជាន់ភ្លើង បាទ! ។

ដារ៉ា ៖ ដល់ពេលអញ្ចឹងទៅ អាអ្នកដែលដើរជាន់ភ្លើងនៅរស់?

សេង ៖ បាទ! នៅរស់ៗ ។

ដារ៉ា ៖ អា ១ ១ នាក់ខាងមុខដែលគេចភ្លើងគេយកវៃចោល?

សេង ៖ បាទ! យកវៃចោល វៃទំនប់ហ្នឹងឯង ។

ដាគា ៖ អ្នកក្រោយហ្នឹងឈឺមែនទែនអី?

សេង ៖ ទេ! មិនដឹងដែរនាង ។

ដារ៉ា ៖ អញ្ចឹងហ្នឹងពូឃើញផ្ទាល់ភ្នែក?

សេង ៖ ផ្ទាល់ភ្នែក ។

ដារ៉ា ៖ ហើយគាត់រ៉ាល់នៅហ្នឹងដែរ?

សេង ៖ ទេ! គាត់រ៉ាល់គេអ្នកក្ដាប់បញ្ជារួច គាត់ច្រើនតែដើរពាក់មួកស្លឹកត្នោត ហើយដើរគ្មានអ្នកណាដឹងថាគា រ៉ាល់ ទេចុះយប់ ។

ដារ៉ា ៖ បាទៗ!

សេង ៖ ក៏ប៉ុន្តែចំណាំមើលតែចបដឹងហើយ បើសិនជាពុចបបាំប់ៗៗរត់ អាហ្នឹងរៀបចំឲ្យហើយគាត់រ៉ាល់មកដល់ហើយ ។

ដារ៉ា ៖ អ្ហូ! យើងចាំស្ដាប់សំលេងចបគេ?

សេង ៖ បាទ!ចាំស្តាប់គេបើយើងនៅកណ្តាល យើងនៅកណ្តាលយើងចាំស្តាប់ឧបមាថាម៉ោពីនេះយើងចាំស្តាប់ពីជើង បើពីជើងព្ធចបបឹប១ ១ ១អ៊ូ!រត់ជាន់គ្នាអីយ៉ៅ គាវ៉ាល់ម៉ោហើយអានេះក៏បឹប១ ១ ១ទៅគ១គ្នាទៅ កាលណា គាវ៉ាល់ ទៅហួសទៅអានេះរាងធូបន្តិចទៅរាងបិកប៉ុក១ទៅ ព្ធប្រធានកងយើងគេសួរថាម៉េចហើយ? បងអើយខ្ញុំជិតរួចហើយ ខ្ញុំនៅសល់តែ២គីកទៀតទេ ព្រោះវាវាស់ម៉ែត្រគីបនោះ ឧបមាថាយើងតម្រូវឲ្យ៣ម៉ែត្រគីប ទាល់ជីកបាន១ម៉ែត្រកន្លះបានមានសិទ្ធិឡើងម៉ោហូបបាយបានបើបានតែ១ម៉ែត្រគីបមិនអាចទេ ដូច្នេះមួយថ្ងៃរួច៣ម៉ែត្រគីបរួចស្មើណាឡើងស្មើ ហ្នឹងបើមិនរួចទេ កាប់ទាល់តែរួច ។

ដារ៉ា ៖ កាប់ទាល់តែរួច?

សេង ៖ បាទ!

ដារ៉ា ៖ អញ្ចឹងពូអាចដឹងបានពីស្ថានភាពអ្នកម៉ោលើកទំនប់ត្រពាំងថ្មហ្នឹង តាមសហករណ៍មានសភាពខុសគ្នាយ៉ាងម៉េចជាមួយនឹងខាងតំបន់?

សេង ៖ ទេ!ពេលហ្នឹងដូចជាថាខ្ញុំវាឆ្ងាយដែរណាស់ ខ្សែគ្រៀមខ្ញុំមកនៅនេះ ដល់សហករណ៍គេរាយពីត្រឹមស្ពានទី២ពីអីម៉ោលិចនេះទៅខ្ញុំឆ្ងាយរាប់គីឡូដែរណាស់ ។

ដារ៉ា ៖ អញ្ចឹងខាងសហករណ៍ហ្នឹងពីស្ពានទីប៉ុន្មានទៅពូ?

សេង ៖ វាលើក វា២-៣សារ វាអត់មានតែ១សារទេ វាលើកទៅនេះទៅ រួចទៅយើងលើកទៅនោះទៀតបានត្រឹមរហូតបានជិតពន្ធែនោះណ៎ វាច្រើនកន្លែងច្រើនកន្ទាក់ ក៏ប៉ុន្តែខ្ញុំចាំបានពេលសហករណ៍ស្រុកថ្មពួកហ្នឹងដូចជាមានឈ្មោះ ខាន់ មួយ ខាន់ហ្នឹងអ្នកស្វាយសរតូច ស្វាយសរភូមិស្វាយសរ ឃុំផ្គាំ ។

ដារ៉ា ៖ គាត់នៅរស់ដែរ?

សេង ៖ បាទ!គាត់នៅ ។

ដារ៉ា ៖ ស្វាយសរ ឃុំអីគេស្វាយសរ?

សេង ៖ នៅឃុំផ្គាំ ស្រុកស្វាយចេក សព្វថ្ងៃស្វាយចេក បើពីមុនថ្មពួក ។

ដារ៉ា ៖ អញ្ចឹងឈ្មោះ ខាន់ ហ្នឹងឯងដែលគាត់សហករណ៍នាំចល័តសហករណ៍ម៉ោ?

សេង ៖ បាទៗ!នាំចល័តសហករណ៍ម៉ោ ក៏ប៉ុន្តែមិនដឹងជាគិតប្រធានឬក៏គិតម៉េចៗទៀត ប៉ុន្តែក្នុងនាមគាត់ប្រាប់ថាអ៊ូ!អាពួកនេះធ្វើចេះៗ ប៉ុនមិនដឹងថាឋានៈគាត់ជាអ្នកគ្រប់គ្រងផ្ទាល់ឬក៏ជាបន្តអីទេ ប៉ុនគិតគាត់ជាកម្មាភិបាលម្នាក់នៅក្នុងឯង ។

ដារ៉ា ៖ បាទ!ឈ្មោះ ខាន់ ហ្នឹងពូធ្វើម៉េចបានពូអាចស្គាល់គាត់ ពូដែលស្គាល់គាត់ពីមុនម៉ោឬក៏ម៉េច?

សេង ៖ អត់ទេ!បើនិយាយវាវែង ពិបាកវែងឆ្ងាយណាស់ ។

ដារ៉ា ៖ និយាយសង្ខេបបន្តិចពូ?

សេង ៖ បាទ!សង្ខេបពេលនោះខ្ញុំស្រឡាញ់ បានទៅស្រឡាញ់នារីសហករណ៍គាត់ទៅ ដល់ទៅសួរទៅថាគាត់ប្រធានទៅប៉ុនហ្នឹងទេ ។

ដារ៉ា ៖ អ៊ូ!តាមរយៈអញ្ចឹង?

សេង ៖ បាទ!ខ្ញុំស្រឡាញ់ ដល់នេះខ្ញុំសួរប្រធានឈ្មោះអី ឈ្មោះ ខាន់ ។

ដារ៉ា ៖ បានរៀបការដែរ គ្រួសារពូរាល់ថ្ងៃនេះ?

សេង ៖ អត់ទេៗ!បែកបាក់គ្នាហើយ ។

ដារ៉ា ៖ អញ្ចឹងខាងសហករណ៍គេលើកដោយឡែកទៅ ចល័តសហករណ៍គេលើកដោយឡែកទៅ ចល័តតំបន់លើកដោយឡែកទៀតពូ?

សេង ៖ បាទៗ!ដោយឡែកពីគ្នា ។

ដារ៉ា ៖ អញ្ចឹងពូនៅក្នុងចល័តតំបន់ទេ អញ្ចឹងការហូបចុកអីអត់មានខ្វះខាតទេ?

សេង ៖ បាទ!អត់បញ្ហាទេ ។

ដារ៉ា ៖ អញ្ចឹងបើខ្វះខាតៗតែខាងកសិករ?

សេង ៖ បាទ!ខាងកសិករ ហើយនៅហ្នឹងខ្វះខាតៗដូចថាគ្នាកម្លាំងទី២ កម្លាំងទី៣ វាមានកម្លាំង ទី១ កម្លាំងទី២ កម្លាំងទី៣ ។

ដារ៉ា ៖ អញ្ចឹងទៀត?

សេង ៖ បាទ!ដូចខ្ញុំរៀបរាប់ហើយ អាចាប់ទី៣ឡើងអាហ្នឹងកម្លាំងទី១ ហូបម៉ាឆ្អែត អាកម្លាំងទី២រាងខ្សោយបន្តិចបានមួយថ្ងៃ២កំប៉ុង អាកម្លាំងទី៣នោះក្រោមហ្នឹងបន្តិច ។

ដារ៉ា ៖ អាហ្នឹងសម្រាប់ចល័តតំបន់?

សេង ៖ ចល័តតំបន់ ។

ដារ៉ា ៖ ចុះចល័តសហករណ៍គេបែងចែកអញ្ចឹងដែរ?

សេង ៖ អត់ដឹងទេ!ព្រោះសហករណ៍គេគ្រប់គ្រងផ្សេង ខ្ញុំឯនោះផ្សេងវាអត់ដឹង អត់ដឹងថាគេបែកចែកម៉េចៗអត់ដឹង ។

ដារ៉ា ៖ ចុះពូអាចមើលឃើញទេថាចល័តសហករណ៍ធ្វើការជាមួយគ្នាអាចមើលគ្នាឃើញទេ?

សេង ៖ ឃើញតាស់! ។

ដារ៉ា ៖ អញ្ចឹងឃើញជារូបរាងមនុស្សហ្នឹងវាយ៉ាងម៉េចដែរ?

សេង ៖ អ៊ូ!ពិបាក ។ ស្គមៗស៊ិតកំព្រឹងៗ ។

ដារ៉ា ៖ អាហ្នឹងគឺចល័តសហករណ៍ហើយមើលតាម?

សេង ៖ ចល័តសហករណ៍ ។

ដារ៉ា ៖ បើចល័តតំបន់អត់មានរាងអញ្ចឹងទេ?

សេង ៖ ចល័តតំបន់មិនសូវទេ ។

ដារ៉ា ៖ អត់មានរាងកំព្រឹងៗ?

សេង ៖ មិនសូវទេៗ បើមានៗភាគតិច ។

ដារ៉ា ៖ អញ្ចឹង?

សេង ៖ បាទ!មានភាគតិច ប៉ុនអាខ្លះស្គមខ្លាំងដែរ ៣ម៉ែត្រគឺបទៅព្រេចៗ បាទ!ស្គមខ្លាំង បើយើងនៅសហករណ៍មានបានគ្រប់គ្រាន់ដូចគេទេ គាត់ស្គមកំព្រឹងៗ ។

ដារ៉ា ៖ អញ្ចឹងពូម៉ោលើកនៅហ្នឹង គាវ៉ាល់ គាត់ដើរមើលរហូតហ្នងពូ?

សេង ៖ អត់ទៀងទេ ព្រោះកន្លែងគាត់នៅមួយគេហៅ រោងម៉ាស៊ីន គាត់នៅតែរោងម៉ាស៊ីន កាបា៉តហ្នឹងរោងម៉ាស៊ីនចាស់ពីដើមដាក់អង្ករ ហើយគាត់នៅនោះ ។

ដារ៉ា ៖ អ៊ូ!ឆ្ងាយទេពីកន្លែង?

សេង ៖ ទេ!នៅជិតដែរ ចេញពីត្រពាំងថ្មម៉ោដល់បន្តិច ដល់ជិតលូរមួយៗគាត់នៅខាងត្បូងជិតអាម៉ាជួរចេតិយ៍ ឃើញគេធ្វើចេតិយ៍ ។

ដារ៉ា ៖ ឥឡូវ?

សេង ៖ បាទ!បើគិតទៅវ៉ានៅខាងមុខវត្តចំ មុខវត្តត្រពាំងថ្ម ខាងលិចមុខវត្តត្រពាំងថ្មប្រហែលជាយើងថា៣-៤០០ម៉ែត្រគាត់នៅហ្នឹងឯង ។

ដារ៉ា ៖ អញ្ចឹងបើនិយាយទៅការលើកទំនប់ត្រពាំងថ្មហ្នឹង សំខាន់គឺចល័តតំបន់ហ្នឹងហើយដែលថាអ្នកធ្វើដំបូងដើមដៃអីអញ្ចឹង?

សេង ៖ បាទៗ!គឺចល័តតំបន់ ។

ដារ៉ា ៖ ហើយចល័តសហករណ៍នេះយកម៉ោក្រោយទេ?

សេង ៖ បាទ!យកម៉ោក្រោយ ។

ដារ៉ា ៖ តែបើទោះបីជាចល័តតំបន់ ឬចល័តសហករណ៍ក៏ដោយ គឺនៅក្រោមការគ្រប់គ្រង របស់តាវ៉ាល់ ទាំងអស់ ។

សេង ៖ បាទៗ!

ដារ៉ា ៖ នៅក្នុងហ្នឹងពូបានរៀបរាប់ឈ្មោះ តាហ៊ីង ជាលេខាតំបន់អញ្ចឹង?

សេង ៖ តា ហ៊ីង ហ្នឹងពេលហ្នឹងគេហៅប្រធានតំបន់ ។

ដារ៉ា ៖ ប្រធានតំបន់?

សេង ៖ បាទ!

ដារ៉ា ៖ គាត់មានចុះម៉ោមើលម៉ោអីផ្ទាល់ទេ នៅក្នុងការលើកតំនប់ហ្នឹងពូ?

សេង ៖ ឃើញម៉ោមួយដង ពេលនោះម៉ោកាលហ្នឹងចិនចុះម៉ោ ។

ដារ៉ា ៖ អ្ហូ!?

សេង ៖ បាទ!ឈ្មោះស្អីទេ គេថាស្វាគមន៍យ៉ាំងកក់ក្ដៅសមាក់មិត្ត ឈឹម យ៉ុងគុយ ។

ដារ៉ា ៖ អ្ហូ!ឈិន យ៉ាំុងគុយ?

សេង ៖ ឈិន យ៉ាំុងគុយគេចុះម៉ោបើកឡានបើកអីម៉ោ ម៉ោដល់អាងត្រពាំងថ្មហ្នឹងម៉ោ គេឃើញចល័តយើង កាលនោះតាវ៉ាល់ ឲ្យៗជាងដេរមួកស្លឹកត្នោតយើង ស្លឹកត្នោតគេដាក់បូរក្រហមៗ អាចិននោះគេចង់បានដែរ ។

ដារ៉ា ៖ អញ្ចឹង?

សេង ៖ បាទ!ចិនគេចង់បានមួកស្លឹកត្នោតដែរ គេពាក់ យើងធម្មតាមិនដាក់អាខ្សែចងចង្ការនេះម៉ោមុខទៅចេះ ចិនគេពាក់យកអាខ្សែហ្នឹងទៅក្រោយ ពួកខ្ញុំនាំគ្នាសើច គេប្រាប់ថាអ្ហូ

សើចមិនបានទេ ឯងមើលអានេះឆ្អួតទេចុះខ្ញុំនៅអាយុតិចដែរនោះ តិចអានេះឆ្អួតទេ ពាក់យកអាមុខទៅក្រោយថាស្វាត់ៗទេ បានជាតាវ៉ាល់ មិនថាម៉េចព្រោះតាវ៉ាល់ គាត់មិនចេះចិនដែរនោះ ។

ដារ៉ា : តាវ៉ាល់ ចេះចិនដែរ?

សេង : អ្ហូ!អត់ចេះទេ បានគាត់ចេះញ៉ឹមៗ ស្វាគមន៍ៗៗ ចេះតែប៉ុនហ្នឹងសុខសប្បាយៗៗ ។

ដារ៉ា : អ្ហូ!ចិនហ្នឹងនិយាយខ្មែរ?

សេង : ចិន ស្វាគមន៍ៗ សុខសប្បាយៗ ។

ដារ៉ា : អាហ្នឹងម៉ោជាមួយតាហ៊ុីន?

សេង : បាទ!ជាមួយ តាហ៊ុីន មួយដង ។

ដារ៉ា : អ្ហូ!ក្រៅពី តាហ៊ុីន មានអង្គការណាធំម៉ោពីលើទៀតម៉ោមើលម៉ោអីពូ?

សេង : ដូចជាមិនដែលឃើញមាន ដូចជា មូស សម្បត្តិហើយនឹងប្រធានភូមិភាគហ្នឹងក៏មិន ដែលឃើញ ។

ដារ៉ា : អត់ឃើញចូលមកដល់ហ្នឹងសោះហ្នុង?

សេង : អត់ទេ!គ្រាន់លខ្ញុំរវល់ពេលឆ្ងាយគេម៉ោដល់ណាណីអត់ដឹងទេណាស់ ។

ដារ៉ា : ទេ!ចង់និយាយថាម៉ាំរយៈពូនៅហ្នឹងហ្នុង?

សេង : អត់ដែលឃើញទេ ។

ដារ៉ា : ឬក៏ធ្លាប់ឮប្រធានវរៈរបស់ពូនិយាយពីរឿងអ្នកធំអី អង្គការអីចុះម៉ោមើលដែលឮ?

សេង : មិនដែលឮទេ ក៏ប៉ុន្តែដល់អាចុងហ្នឹងខ្ញុំវាដូចជាចាប់អារម្មណ៍បន្តិចទៅ លើកកាច់ជ្រុង ចាប់ពីទី១ទី២ នេះចាប់ដល់ទៅ៨កម្ទាំង ៨កម្ទាំងនេះកម្ទាំងគិតទៅវា មុនដឹបូងវា បញ្ជូនទៅ១០០នាក់ទេ ទៅនៅកូនក្មេង ពេលនោះសភាពការណ៍ដូចជាមិនប្រក្រតីដែរ កាលហ្នឹង ។

ដារ៉ា : បាទ!?

សេង : ដែល សោ ញ៉ឹម ហើយជាមួយនឹង សោ ភឹម ហ្នឹងក៏ប៉ុន្តែដល់យកទៅនោះបញ្ជូនទៅ ដល់ចូល២-៣០០នាក់ ដល់ដឹកៗទៅដល់ត្រើយ ដកយកម៉ោវិញ ។

ដារ៉ា : អញ្ចឹង?

សេង ៖ បាទ!អាហ្នឹងគឺខ្ញុំរត់ការណ៍ហ្នឹងឯង ។

ដារ៉ា ៖ រត់ការណ៍ម៉េចខ្ញុំស្ដាប់អត់ទាន់ដែរពូ?

សេង ៖ កម្លាំងគិតទៅ ពេលដែលលើកអាងត្រពាំងថ្ម លើកជិតរួចហើយចាប់ផ្ដើមលើកពីស្ពានទី១ ទៅដល់ភូមិពាមរ ពេលនោះក៏តាវ៉ាល់ គេចាប់ផ្ដើមបញ្ជូនកម្លាំង១០០នាក់ទៅនៅភ្នំកូនក្មែង ។

ដារ៉ា ៖ តាវ៉ាល់ បញ្ជូន?

សេង ៖ បាទ!តាវ៉ាល់ ជាអ្នកបញ្ជូនទៅ ប្រាប់ទៅ គាត់មានទៅខ្លួនគាត់អីប្រាប់ទៅប្រាប់ប្រធានវរៈ ថាណែ៎អ្នកឯងចេះៗប្រាប់ថាទៅនោះ១០០នាក់អីទៅ សុទ្ធតែមនុស្សប្រុសអត់យកមនុស្សស្រីទេ ទៅដល់នោះក៏មិនមានឃើញធ្វើអី ។

ដារ៉ា ៖ នៅភ្នំក្មែងហ្នឹង?

សេង ៖ បាទ!ទៅក៏លើកប្រព័ន្ធភ្លឺ ប្រព័ន្ធកែង ត្រពាំងណាមួយធំទៅចុះគ្នារាប់រយ ទាញចបរាងខ្លួនបិទៗក៏បាចត្រពាំងក៏យកត្រីយកអីមៅ ។

ដារ៉ា ៖ អញ្ចឹង?

សេង ៖ បាទៗ!ដល់ក្រោយម៉ោទៀតនៅបានប្រហែលជា៣-៤ខែទៅ តានេះឲ្យដកម៉ោវិញ ។

ដារ៉ា ៖ អញ្ចឹងពេលដែលដក១០០នាក់ទៅភ្នំក្មែងហ្នឹង ទៅទាំងពូដែរ?

សេង ៖ ខ្ញុំអត់បានទៅទេ ក៏ប៉ុន្ដែខ្ញុំតាវ៉ាល់ សម្រាប់ប្រើ ។

ដារ៉ា ៖ អ្ហូ!សម្រាប់ប្រើពី?

សេង ៖ ប្រើឲ្យដកកម្លាំង ។

ដារ៉ា ៖ ដកកម្លាំងដកអីពីត្រពាំងថ្មហ្នឹងទៅភ្នំក្មែង?

សេង ៖ បាទៗ!ដល់នោះពេលដែលគាត់ឲ្យដកកម្លាំងហ្នឹង គាត់ប្រាប់ប្រធានវរៈ ប្រធានវរៈជាអ្នកចាត់ចែង ។

ដារ៉ា ៖ បាទ!

សេង ៖ ក៏ប៉ុន្ដែប្រសិនបើដកកម្លាំងនោះវិញគាត់ប្រើខ្ញុំ ហើយខ្ញុំក៏តាមកម្លាំងម៉ោវិញ ។

ដារ៉ា ៖ អ្ហូ!តាមកម្លាំងពីកូនក្មែងម៉ោ?

សេង ៖ បាទ!ពីកូនក្មែងម៉ោនេះវិញ ។

ដារ៉ា ៈ អាសភាពការណ៍ហ្នឹងពូយល់ថាយ៉ាងម៉េចដែរ ក្រោយម៉ោពូមានដឹងថាហេតុអីបានមានដកអញ្ចឹង?

សេង ៈ ដល់ទៅ បញ្ជូនទៅ១០០ហើយ បញ្ជូនទៅទៀតៗដល់សភាពការណ៍ ដល់អាមួយហ្នឹងវាថាសភាពការណ៍ដូចមិនប្រក្រតី ដល់ក្រោយម៉ោទៀតបានពុចាប់តាញឹម ចាប់តាភឹម ចាប់តាដាល ចាប់តាអីវ៉ែបណ្ដើរៗទៅ ធ្លាក់ដល់បណ្ដើរៗហើយនេះ ចាប់ប្រធានវរៈ ចាប់ពួកតារ៉ិត តាស្រេះឯណានេះ ប៉ុនតាស្រេះហ្នឹងអ្នកដូចប្រេះហ្នឹងគេរត់ រត់ទៅក៏អត់រួចដែរ៦-៧នាក់ ។

ដារ៉ា ៈ អញ្ចឹង?

សេង ៈ អារ៉ើត អាស្រេះ អាធួន អាវ៉ៃ បាទ!គេរត់ អាហ្នឹងគេសុទ្ធតែប្រធានវរៈ ប្រធានវរៈទី ។

ដារ៉ា ៈ បាទ!នៅខាងណា?

សេង ៈ អាហ្នឹងនៅអាងត្រពាំងថ្មហ្នឹងឯង ។

ដារ៉ា ៈ អញ្ចឹងដែរ ដែលគេម៉ោលើកដែរ?

សេង ៈ បាទ!ម៉ោលើកដែរ ក៏ប៉ុន្តែគេនៅវរៈ២ ។

ដារ៉ា ៈ អ្អូ!វរៈ២?

សេង ៈ បាទ!ខ្ញុំវរៈ១ ។

ប្រុញ ៈ អត់ទោសពូ កាលហ្នឹងពីណាគេដែលម៉ោចាប់តាញឹមតាអីពូ?

សេង ៈ គេអត់មានចាប់ផងហ្នឹង ដូចតាវ៉ាល់តាអីគេ តែសំបុត្រហ្នឹង សំបុត្រអញ្ជើញអង្គការទៅប្រជុំទៅ ទៅបាត់ខ្លួនបណ្ដោយ អត់ឃើញមានអ្នកណាម៉ោវិញ ។

ដារ៉ា ៈ បាទ!អញ្ចឹងពេលហ្នឹងគឺថាដោយសារមានការចាប់ខាងលើៗហ្នឹងដែលពូគិតថាស្ថានភាពវាមិនប្រក្រតី ដែលការដកកម្លាំងពីត្រពាំងថ្មទៅភ្នំក្លែងអញ្ចឹងពូ?

សេង ៈ បាទៗ!ដកពីកូនក្លែងមកវិញ ។

ដារ៉ា ៈ ដកពីកូនក្លែងម៉ោវិញ?

សេង ៈ បាទ!

ដារ៉ា ៖ អាចថាដកកម្លាំងពីត្រពាំងថ្មទៅទប់នឹងកូនក្លែងហ្នឹង អាចថាជាផែនការណ៍ឬក៏យ៉ាងម៉េចទៅពូ បើតាមពូគិតទៅ?

សេង ៖ វាៗដឹងអត់ដល់ បើតាមការស្មានវាខ្លាចតែខុស ព្រោះការស្មានវាខុស ដូច្នេះមិនចង់ស្មានទេ ។

ដារ៉ា ៖ អ៊ូ!អត់អីទេពូ?

សេង ៖ ព្រោះយើងឮថាវា សភាពការណ៍បើខ្លះមួយចំនួន ប៉ុន្តែខ្ញុំមិនថាយកជាផ្លូវការណ៍ទេ បើម៉ាចំនួនអ្នកដែលគេដឹងចិត្តខ្ញុំ គេថាប្រុងណាស្អីៗទៅណា៎ ។

ដារ៉ា ៖ ចុះអាពេលដែលឮថាចាប់ប្រធានភូមិភាគ រស់ ញឹម អី ជាល ហ្នឹងម៉ោពូអាហ្នឹងវាចូលដល់ឆ្នាំណាហើយពូ?

សេង ៖ អាហ្នឹងចូល៨៨ ។

ជិតខាង ៖ ៧៨?

ដារ៉ា ៖ ៨០ឬ ៧០?

សេង ៖ អ៊ូ!ឆ្នាំ៧៨ ។

ដារ៉ា ៖ ចូល៧៨ហើយ?

សេង ៖ បាទ!៨ហើយ ។

ដារ៉ា ៖ ចូល៧៨ហើយ ប៉ុន្តគ្រាន់ដើមឬកណ្តាល ចុងអីអាចបានទេ?

សេង ៖ ប្រហែលជាចូលជិតដល់ចុងហើយ អាឆ្នាំ៧៨ហ្នឹង ព្រោះបណ្តើៗទៅដល់៧៩បានខ្ញុំបានគ្រួសារ ចាប់បាន១ឆ្នាំ បានខ្ញុំឈប់ រើពីនេះទៅបានទៅនៅចំការកប្បាសកងវ៉ា ។

ដារ៉ា ៖ ទៅកងវ៉ាវិញ?

សេង ៖ បាទ!ទៅកងវ៉ា ។

ដារ៉ា ៖ អញ្ចឹងនៅក្នុងត្រពាំងថ្មហ្នឹងពូលើកទាល់តែអាងហ្នឹងចប់សព្វគ្រប់ឬក៏យ៉ាងម៉េច?

សេង ៖ គិតទៅខ្ញុំទៅក្រោយគេ ព្រោះដែលគេលើករួចគេទៅបាត់ ដល់ខ្ញុំនៅធ្វើស្ពាន ធ្វើទាល់ រួចធ្វើទាល់តែអស់ស៊ីម៉ង់ ធ្វើទាល់តែអស់ដែកបានខ្ញុំឈប់ ។

ដារ៉ា ៖ គ្រប់ស្ពានទាំង៣ហ្នឹងហ្មង?

សេង ៖ បាទ!គ្រប់ស្ពានទាំង៣?

ដារ៉ា : ចុះពេលដែលធ្វើស្ពានទាំងពាហ្នឹងហើយពូ ទំនប់ ខ្នងទំនប់ខ្នងអីលើកហើយឬនៅ?

សេង : បាទ!ហើយ ប៉ុនវាមិនទាន់ហើយស្រួលបួលទេណា៎ គេទុកចំនួនប្រហែលជា២-៣០០នាក់អីទៅសម្រាប់តែបំពេញ ។

ដារ៉ា : សម្រាប់បំពេញ?

សេង : បាទ!បំពេញអាហ្នឹងត្រង់ស្ពាន ខ្នង១មើលអាណាដែលទាប អាណាដែលស្គី១ហ្នឹងគឺអា២-៣០០នាក់ហ្នឹងឯងជាអ្នកបំពេញ ។

ដារ៉ា : បាទ!សម្រាប់បំពេញហ្នឹងគឺនៅជាមួយទាំងចល័តសហករណ៍ នៅជាមួយគ្នានៅក្នុង ហ្នឹង?

សេង : បាទ!ពេលនោះចល័តសហករណ៍គេដកចេញអស់ហើយ ។

ដារ៉ា : អញ្ចឹងទៀត?

សេង : បាទ!គេដកទៅមូលដ្ឋានគេវិញរៀង១ខ្លួន ។

ដារ៉ា : អញ្ចឹង អាហ្នឹងគឺចុង៧/៨ហើយ?

សេង : បាទ!ចុង៧/៨ហើយ ក៏ប៉ុន្តែបើមាននៅបើថ្មពួកដកមុន ប្រហែលជានៅព្រះនេត្រព្រះព្រះនេត្រព្រះដកក្រោយគេ ។

ដារ៉ា : អ៊ូ!ព្រះនេត្រព្រះដកក្រោយគេអញ្ចឹង?

សេង : បាទ១!ចេញក្រោយគេ បើខាងថ្មពួកចេញទៅមុន ។

ដារ៉ា : អញ្ចឹងអ្នកដែលនៅក្រោយគេ នៅកន្លែងត្រពាំងថ្មហ្នឹងគឺស្រុកព្រះនេត្រព្រះ?

សេង : បាទ!

ដារ៉ា : សហករណ៍ស្រុកព្រះនេត្រព្រះ?

សេង : បាទ!ក៏ប៉ុន្តែមិនបានដល់ស្ពានទី១ទេណា៎! ។

ដារ៉ា : បាទ!?

សេង : អាហ្នឹងបានម៉ោដល់ចាប់ពីយើងស្ពានទី២ ឬក៏គេហៅដៃស្ទូ បាទ!ហ្នឹងទៅនោះទេទៅផ្នែកខាងលិច ។

ដារ៉ា : អញ្ចឹងពូ ពេលហ្នឹងពូធ្វើស្ពានធ្វើអីហើយអស់ហើយ បានពូត្រូវគេដកឲ្យម៉ោធ្វើកន្លែងផ្សេង?

សេង : បាទ!ពេលហ្នឹងស្ពានវាធ្វើអត់ទាន់រួចទេ ក៏ប៉ុន្តែវាខូះ ។

ដារ៉ា ៖ ខ្វះអីគេពូ?

សេង ៖ វាខ្វះស៊ីម៉ង់ ខ្វះដែក ណាមួយសភាពការណ៍តាវ៉ាល់ ក៏បាត់ខ្លួន ។

ដារ៉ា ៖ អ្ហូ!អញ្ចឹងពេលដែលតាវ៉ាល់ បាត់ខ្លួនហ្នឹងសភាពការណ៍នៅកន្លែងទំនប់កន្លែងអីហ្នឹងទៅជាយ៉ាងម៉េចទៅពូ?

សេង ៖ វាទៅអានាធិបតេយ្យ វាច្របូកច្របល់គ្មានអ្នកណាគ្រប់គ្រងអ្នកណា អត់មានណាអីណាវាច្របូកច្របល់តិចទៅ បានគេបញ្ជូនអ្នកនិរតីម៉ោគ្រប់គ្រងវិញម្តង ។

ដារ៉ា ៖ អញ្ចឹងពេលដែលបញ្ជូនអ្នកនិរតីម៉ោគ្រប់គ្រងហ្នឹងពូនៅហ្នឹងដែរ ឬម៉េច?

សេង ៖ បាទ!ពេលនោះខ្ញុំនៅដែរ ក៏ប៉ុន្តែខ្ញុំនៅមិនបានយូរទេ ខ្ញុំនៅបានប្រហែលជា៤-៥ខែ គេដក វាអត់ស៊ីម៉ង់ អត់ដែក អត់ដាង នៅតែអ្នកដែលរែកទឹក នៅតែអ្នកដែលចង ដែកចងអី នៅខ្វះទៅ ហើយគេក៏ដកខ្ញុំទៅនៅចំការកប្បាសកងវ៉ា បន្ទាយមានជ័យ យើងស្វាយនេះ ។

ដារ៉ា ៖ អញ្ចឹងពេលដែលពួកនិរតីម៉ោដល់ហ្នឹង ប្រហែលនៅក្នុងចុងឆ្នាំ៧៨អញ្ចឹង?

សេង ៖ បាទៗ!ខ្វង់ហ្នឹងឯង ពីឆ្នាំ៧៨ដល់ឆ្នាំ៧៩ហ្នឹងឯង ។

ដារ៉ា ៖ អញ្ចឹងពេលដែលពួកនិរតីចូលម៉ោហ្នឹង ប្រធានរបស់ពូឈ្មោះ ខូវ ឈ្មោះ វន ទៅណាម៉ោណា?

សេង ៖ គេបញ្ជូនឲ្យទៅជាមួយខ្ញុំដែរ ក៏ប៉ុន្តែគាត់អត់មានតំណែងទេ ។

ដារ៉ា ៖ អត់មានតំណែងទេ?

សេង ៖ បាទ!

ដារ៉ា ៖ អត់មានចាប់ទេ?

សេង ៖ ចាប់ៗក្រោយទៀត បាទ!ពេលដែលបញ្ជូនម៉ោដល់ភ្លាមគឺមានប្រធានដែលម៉ោជំនួសតាវ៉ាល់គឺឈ្មោះ តាពាល់ ។

ដារ៉ា ៖ អ្ហូ!តាពាល់?

សេង ៖ បាទ!តាពាល់នេះគឺជំនួស តាវ៉ាល់ បាទ!ចាប់វ៉ាល់បាន នៅតាពាល់ជំនួសតាវ៉ាល់ ។

ដារ៉ា ៖ ឈ្មោះពាល់អញ្ចឹង?

សេង ៖ បាទ!ពាល់ តាពាល់ អាហ្នឹងគឺមកភូមិភាគនិរតីហ្នឹងឯង ។

ជាតា ៖ ឆ្នាំ៧៨ហ្នឹង?

សេង ៖ បាទៗ!

ដារ៉ា ៖ អញ្ចឹងគ្រប់គ្រងផ្ទាល់កន្លែងត្រពាំងថ្មទាំងមូលដែលជំនួសតាវ៉ាល់ហ្នឹងគឺតាពាល់ហ្នឹង?

សេង ៖ បាទ!គឺតាពាល់ ។

ដារ៉ា ៖ បន្ទាប់ពីតាពាល់ មានអ្នកណាទៀត?

សេង ៖ ទេ!អត់មានទេ ចប់ពីនោះគឺមានតែប្រធានវរៈ រៀបចំដូចមុនដដែល ។

ដារ៉ា ៖ រៀបចំដូចមុនប្រធានវរៈ?

សេង ៖ បាទ!

ដារ៉ា ៖ អញ្ចឹងពេលដែលប្រធានវរៈហ្នឹងមានអ្នកណាដែលនៅស្គាល់ឈ្មោះខ្លះ?

សេង ៖ បាទ!ប្រធានវរៈខ្ញុំឈ្មោះ តាចេង មួយទៀត តាចេងគេបំបិទមេដៃមួយ តាចេង តានិន តាចេងនឹងតានិន គឺប្រធានវរៈមួយ ។

ដារ៉ា ៖ តានិន?

សេង ៖ បាទ!

ដារ៉ា ៖ អាហ្នឹងវរៈមួយ?

សេង ៖ បាទ!

ដារ៉ា ៖ វរៈមួយគឺវរៈរបស់ពូ?

សេង ៖ បាទ!វរៈរបស់ខ្ញុំហ្នឹងហើយ ។

ដារ៉ា ៖ អ្ហូ! ចុះវរៈផ្សេងៗទៀតអ្នកណាពូអាចស្គាល់ទេ?

សេង ៖ ស្គាល់មិនអស់ទេ ពេលនោះវាបែកឆ្ងាយគ្នាហើយ ពេលដែលគេម៉ោដល់ភ្លាមគេមានតួនាទីស្រេចបាច់ហើយ គេរៀបចំស្រេច ។

ដារ៉ា ៖ ម៉ោស្រេចគឺដាក់ហ្នឹងហ្មង?

សេង ៖ បាទ! ម៉ោដល់គឺបញ្ចូលហ្នឹង ។

ដារ៉ា ៖ ហើយប្រធានវរៈរបស់ពូពេលហ្នឹង?

សេង ៖ ពេលហ្នឹងគេបញ្ជូន តានិនហ្នឹងគេបញ្ជូនខ្ញុំទៅកងវ៉ា ហើយក៏បាត់ខ្លួនគាត់ទៅ ។

ដារ៉ា ៖ អត់ទេ! ពេលដែលពូនៅត្រពាំងថ្មហ្នឹង ដែលថាមានចេង មានចិន ដែលជាវីរៈរបស់ពូនោះណា៎ ម៉ោគ្រប់គ្រងពូពេលហ្នឹង ខូវហើយនឹងវ៉ន ដែលជាវីរៈពូមុនហ្នឹងគេដកទៅណាឬក៏នៅហ្នឹងដដែល?

សេង ៖ មុនដំបូងនៅធម្មតា ។

ដារ៉ា ៖ តែអត់មានគួនាទីអីទេ?

សេង ៖ បាទ!

ដារ៉ា ៖ លើកដីលើកអីដូចគេទៅ?

សេង ៖ អត់លើកទេ ក៏ប៉ុន្តែដឹងថាគេៗម៉ោៗ គេជាប្រធានហើយ គេនៅតែហូបបាយហូបអីជាមួយយើងធម្មតា ។

ដារ៉ា ៖ បាទ!?

សេង ៖ ពេលដែលដើរទៅមើលកូនចៅវែកទំនប់ កាប់ដុតកាប់ព្រៃអីគេទៅទាំងអស់គ្នា គេទៅ ។

ដារ៉ា ៖ ទៅទាំងតាវ៉ន តា?

សេង ៖ បាទ! ទៅទាំងតាវ៉ន ទៅទាំងនេះ ហើយគេជួនកាលគេទៅ ជួនកាលគេមិនទៅៗស្រេចតែគេ ។

ដារ៉ា ៖ បាទ!?

សេង ៖ បាទៗ! បាននៅហ្នឹង៤-៥ខែបានរួចវាអត់អីៗ បាត់តាវ៉ាល់បាត់អីទៅនេះបានដកពួកខ្ញុំនេះទៅនៅធ្វើចំការកប្បាសកងវ៉ា ។

ដារ៉ា ៖ កងវ៉ា?

សេង ៖ បាទ! រួចបានបាត់តា២នាក់ ។

ដារ៉ា ៖ អញ្ចឹងតាខូវ ហើយនឹងតាវ៉ននេះពេលដែលដកជាមួយពូដែរ ទៅកងវ៉ាទៅកន្លែងដាំកប្បាសហ្នឹងគាត់ទៅជាមួយគ្នាដែរពូ?

សេង ៖ ទៅៗ! បានក្រោយគេដូរ ។

ដារ៉ា ៖ ហើយដកកង ឬក៏គ្រាន់តែដកតែពូហើយប្រធានកង?

សេង ៖ អត់ទេ! ដកកម្លាំងទាំងអស់ ។

ដារ៉ា ៖ កម្លាំងរបស់ពូទាំងអស់ហ្នុង?

សេង ៈ បាទ! កម្លាំងទាំងអស់ទៅធ្វើចំការកប្បាសនៅកងវ៉ា ។

ដារ៉ា ៈ អ្ហូ! បាទ?

សេង ៈ ហើយអាហ្នឹងទុកវាអត់មានដីអត់មានស៊ីម៉ង់ធ្វើ?

ដារ៉ា ៈ អញ្ចឹងមុនពេលដែលពូចេញទៅហ្នឹង អាស្ថានភាពទំនប់អីហ្នឹងមើលទៅដូចហើយឬនៅ ឬក៏យ៉ាងម៉េច?

សេង ៈ ថាហើយទៅចុះ ។

ដារ៉ា ៈ បើសិនជានិយាយភាគរយ ពូគិតថាប៉ុន្មានភាគរយដែលហើយ?

សេង ៈ វាចូល៩៥ភាគរយហើយ ។

ដារ៉ា ៈ អញ្ចឹង?

សេង ៈ បាទ! វាចូលហើយអស់ហើយមានស្អីទៀត វានៅតែស្ពានដែលយើងទឹមធ្វើបាន៣០-៤០ភាគរយ ។

ដារ៉ា ៈ ស្ពានទាំង៣ហ្នឹង?

សេង ៈ បាទ! ស្ពានហ្នឹង ស្ពានទី១ ទី២ ទី៣ហ្នឹងគិតទៅវាធ្វើវាមិនទាន់បានហើយ ធ្វើទឹមបានវាប្រហែល៣០-៤០ភាគរយអី ។

ដារ៉ា ៈ ស្ពានហ្នឹង?

សេង ៈ បាទ! ស្ពានហ្នឹង ។

ដារ៉ា ៈ អញ្ចឹងស្រមាំរយៈពេលធ្វើមិនមានទឹកបុកម៉ោអញ្ចឹង?

សេង ៈ បុក ។

ដារ៉ា ៈ ទឹកបុកម៉ោអញ្ចឹងកន្លែងស្ពានហ្នឹងអត់បានទប់អត់បានអីទេ ហូរទៅហ្នង?

សេង ៈ អត់ទេ! ហូរតាមចិត្តហូរបានអីទេទៅ ។

ដារ៉ា ៈ អត់ទាន់មានបិទជាស្ពានជាអីបានទេ?

សេង ៈ អត់ទេវាធំ ចំហរស្ពានប៉ុនណាប៉ុនណឹ ។

ដារ៉ា ៈ អ្ហូ! ពេលទឹកម៉ោមិនហូរខ្លាំងកន្លែងហ្នឹង?

សេង ៖ បាទ! ហូរខ្លាំងណាស់ ប៉ុនមានខ្វះចេះតែច្នៃបង្ហិលឲ្យបិទបើកៗ អាអ្នកស្រែក្រោមវា បើក អាអ្នកស្រែលើបិទៗ អ៊ីណាទេពេញតែហ្នឹងឯង ។

ដារ៉ា ៖ អញ្ចឹងពេលដែលពូទៅហ្នឹងទំនប់លើកសឹងតែហើយៗ?

សេង ៖ បាទៗ!

ដារ៉ា ៖ ប៉ុន្តែស្ពានទាំង៣ហ្នឹងមិនទាន់ហើយទេ?

សេង ៖ បាទៗ! មិនទាន់ហើយទេ ហើយតែទ្វារទឹក ។

ដារ៉ា ៖ ទ្វារទឹក?

សេង ៖ បាទ! ប៉ុនអាពីលើហ្នឹងមិននេះ នៅអាដើរពីលើថ្មើចាក់កម្រាល ។

ដារ៉ា ៖ ចាក់កម្រាលលើ?

សេង ៖ បាទ! ចាក់កម្រាលលើ ។

ដារ៉ា ៖ អញ្ចឹងទ្វារហ្នឹងធ្វើរួចហើយ?

សេង ៖ បាទ! រួចហើយ ។

ដារ៉ា ៖ យើងអាចបិទបើកអីបានទេ?

សេង ៖ បិទបើកបាន ។

ដារ៉ា ៖ បាទ! យល់ហើយអញ្ចឹង ។

សេង ៖ បាទ!

ដារ៉ា ៖ ហើយចុះពូនៅក្នុងហ្នឹងពូសហករណ៍ហ្នឹង ពូដឹងថាអ្នកណាជាប្រធានចល័តសហករណ៍អី គេម៉ោតាមស្រុកមួយៗពូអាចស្គាល់អ្នកណាជា ចៅហ្វាយស្រុកចៅហ្វាយអីម៉ោគ្រប់គ្រង?

សេង ៖ ខ្ញុំភ្លេចឈ្មោះភ្លេចដែរពេលហ្នឹងគេ ព្រោះពេលនោះគេដក គេចល័តពេលនោះខ្ញុំដឹងថា នៅនឹងស្រុកព្រះនេត្រព្រះគឺឈ្មោះ តាមោង នៅភ្នំស្រុកគឺឈ្មោះតាហាត់ ហើយនៅ ថ្មពួកហ្នឹងគេដកចេញពីចល័តហ្នឹងឯងទៅនៅ ខ្ញុំភ្លេចឈ្មោះគាត់ហើយតាហ្នឹងរាងទាប ជ្រេះ ។

ដារ៉ា ៖ ភ្នំស្រុកអ្នកណាមិញពូ?

សេង ៖ បាទ! នេះភ្នំស្រុក ។

ដារ៉ា ៖ ហ្នឹងអ្នកណាឈ្មោះអី?

សេង ៖ ឈ្មោះតាហាត់ ។

ដារ៉ា ៖ តាហាត់?

សេង ៖ បាទ! អាហ្នឹងប្រធានស្រុក ។

ដារ៉ា ៖ ប្រធានស្រុកហើយហ្នឹង?

សេង ៖ បាទ!

ដារ៉ា ៖ អញ្ចឹងតាមោងនេះគាត់នៅព្រះនេត្រព្រះរហូតហ្នឹងក៏ម៉េច?

សេង ៖ បាទ! ពេលនោះគឺសភាពការណ៍របស់ស្រុកខ្ញុំគឺនៅសល់ក្តាប់បានដែរ ។

ដារ៉ា ៖ បាទ!

សេង ៖ បាទ! ប៉ុន្តែវាមានប្រធាន វាមានរងមានអី ដួនកាលទៅគេដកចេញចូល ប៉ុន្តែខ្ញុំជឿថាពួកហ្នឹងនៅហ្នឹងទល់តែពួកនិរតីចុះម៉ោបានចាប់ផ្តើម ។

ដារ៉ា ៖ អ្ហូ! បានចាប់ផ្តើម?

សេង ៖ បាទ! ដោះដូរ ។

ដារ៉ា ៖ ចុះពូមានធ្លាប់ឮឈ្មោះ យាយថែមទេ?

សេង ៖ បាទ! យាយថែមហ្នឹងគាត់ៗណែ៎!នៅគ្រប់គ្រងខាងស្រុក ខាងនេះស្រុកព្រះនេត្រព្រះ ដែរ ប៉ុន្តែគាត់ចុះដាប់នៅភូមិភ្នំលាប ។

ដារ៉ា ៖ អ្ហូ! គាត់ចុះដាប់តែនៅភ្នំ?

សេង ៖ បើនិយាយទៅឃុំភ្នំលាបៗ ។

ដារ៉ា ៖ គាត់ចុះដាប់កន្លែងហ្នឹង?

សេង ៖ បាទ!

ដារ៉ា ៖ គាត់បានម៉ោត្រពាំងថ្មហ្នឹងដែរពូ?

សេង ៖ ទេដូចមិនដែលឃើញ មិនដែលឃើញម៉ោទេតាថែម ។

ដារ៉ា ៖ ពូស្គាល់គាត់ដែរ?

សេង ៈ ខ្ញុំបើឃើញមុខស្គាល់ ព្រោះឆ្នាំ៧៩ដែលវៀតណាមចូលម៉ោដល់ក្រឡាញ់ដល់អី ខ្ញុំម៉ោពីហ្នឹងខ្ញុំម៉ោពីស្វាយហ្នឹងម៉ោដល់ហ្នឹងខ្ញុំទៅចុះនៅភ្នំលាបហ្នឹងដែរ ។

ដារ៉ា ៈ ចូលរួមកម្លាំងជាមួយយាយចែមហ្នឹង?

សេង ៈ អត់បាន! ។

ជាតា ៈ យាយមួយនេះ(ជាតាបានបង្ហាញរូបថតយាយចែមឲ្យពូសេងមើល) ។

សេង ៈ អូ! (គាត់សើច)ប៉ុនគាត់ឥឡូវអត់មានអញ្ចេះទេ គាត់នៅក្មេងជាងនេះ ។

ដារ៉ា ៈ ហ្នឹង?

សេង ៈ នេះហើយ! នេះយាយចែម ប៉ុនកាលហ្នឹងគាត់អត់មានអញ្ចេះទេ ដែលគាត់រត់ចេញពីនេះគាត់កូនខ្ចីមួយ រត់ចេញទៅពីភ្នំលាបនេះ មានកូនខ្ចីមួយ ។

ជាតា ៈ អញ្ចឹងយាយចែម គាត់មានប្ដីនៅសម័យហ្នឹងដែរ?

សេង ៈ ប្ដីខ្ញុំ! មិនដែលឃើញទេ បើឃើញគាត់ដឹងតែគាត់មានកូនណ៎ា ដែលចេញទៅហើយចោលម៉ូតូ ចោលកង ចោលកាំភ្លើងអាចាស់ៗអីនៅក្នុង ។

ដារ៉ា ៈ អញ្ចឹងពេលពូត្រូវដកម៉ោនៅ មិញថាកងវ៉ាអញ្ចឹង?

សេង ៈ បាទ!

ដារ៉ា ៈ នៅកងវ៉ាដាំកប្បាសហ្នឹង កងរបស់ពូហ្នឹង?

សេង ៈ បាទ!

ដារ៉ា ៈ អញ្ចឹងមេកងពូអីផ្សេងៗទៅណាអស់ពេលហ្នឹង?

សេង ៈ ពេលដល់ហ្នឹងទៅគឺឈ្មោះ តាឡេងៗហ្នឹងមួយ ហើយឈ្មោះតាស៊ីម២ ហ្នឹងជាប្រធានកងចំការកប្បាសកងវ៉ា ដល់ពេលនោះទៅគេស្រាប់តែនិយាយថា បើសិនជាអ្នកណាយកប្រពន្ធគេឲ្យទៅសហករណ៍ បាទ! ខ្ញុំក៏ចាប់ផ្ដើមស្នើរប្រពន្ធខ្ញុំក៏បានទៅ បានហ្នឹងពេលនោះគេរៀបការហ្នឹងប៉ុន្មានទេ ២៥គូរ ។

ដារ៉ា ៈ អូ!?

សេង ៈ បាទ! ការនៅកងវ៉ាហ្នឹងឯង ។

ដារ៉ា ៈ បាទ!?

សេង ៈ ដល់ការនៅកងវ៉ា គេក៏ឲ្យខ្ញុំគ្រប់គ្រងទាំងអស់ហ្នឹងឯង គ្រប់គ្រងអាពួកវ័យកណ្តាល ដល់គេបញ្ជូនទៅ ទៅនៅម្កាក់ដូនលីយើងនេះ ម្កាក់ស្វាយចេក ម្កាក់ដូនលីយើងនេះ ដល់ទៅហ្នឹងទៅ ស្រាប់តែទៅដល់ប្រធានសហករណ៍គេត្រូវគ្នាជាមួយតាភក្រ ដល់ត្រូវទៅស្តាប់សភាពការណ៍ថាវៀតណាមមកហើយៗ ហើយខ្ញុំគេឲ្យគោ ឲ្យរទេះសម្រាប់រត់ទៅគេ ខ្ញុំសួរប្រពន្ធខ្ញុំនេះយើងទៅណា គេថាមិនដឹងស្រេចតែឯង ខ្ញុំថាអ៊ូយ! ខ្ញុំមិនចូលព្រៃទេ ទៅអីទៅក៏វាមិនអី ដល់វាខ្ញុំ កាលដំបូងគេប្រគលឲ្យគោហ្នឹងម៉ានឹម រទេះមួយដល់អញ្ចឹងទៅគេឲ្យអង្ករម៉ាបាវ ឲ្យគ្រាប់សណ្តែកម៉ាបាវ ហើយនឹងស្ករត្នោតហ្នឹងម៉ាកូនពាង រៀបចំស្រេច ខ្ញុំទៅតាមគេខ្ញុំអត់ម៉ោ ខ្ញុំសរសេរសំបុត្រ លិខិតខន្មេសនាមសរសេរដោយខ្លួនឯង ចុះមានអីកម្ពុជាប្រជាធិបតេយ្យ លិខិតខន្មេសនាមខ្ញុំបាទឈ្មោះនេះ សេង សរសេរខ្លួនឯងអញ្ចឹងម៉ោនាំប្រពន្ធខ្ញុំរត់តាំងពីម្កាក់ដូនលីហ្នឹងរត់ម៉ោស្វាយ កាលហ្នឹងប្រធានកងខោខ្មៅ អាវខ្មៅ មួកកាតឹបមួកអីណា ម៉ោដល់កៀកឡាន គេឡានយោធាម៉ោដឹកយាយថែម ហ្នឹងឯងដល់ម៉ោដឹកយាយថែម ខ្ញុំផាកឡានៗគេសួរមិត្តទៅណា? ថាខ្ញុំទៅភ្នំលាប ទៅធ្វើអី ហ៊ឺ!ខ្ញុំទៅមានការតិច ព្វតែថាពួកយួនគេម៉ោដល់ណាដល់ណី ទៅយកបងប្អូន មិត្តឯងមានលិខិតខន្មេសមានអត់? ខ្ញុំថាមានដល់ឲ្យអាហ្នឹងទៅ បែបវាអត់ចេះអក្សរៗវាថាម៉ោនេះមកអញ្ចឹង ឡើងឡានទៅបានទៅជួបអ្នកថែមនៅផ្ទះហ្នឹងឯង រួចបានម៉ោថា ខ្ញុំប្រាប់បណ្តោយខ្ញុំកុហក ។

ដារ៉ា ៈ បាទ!

សេង ៈ កុហកថាមិត្តឯងចាំខ្ញុំផងខ្ញុំទៅរកបងប្អូនសិន ក៏ប៉ុន្តែបើខ្ញុំយូរបាត់ខ្ញុំយូរមិនបាច់ចាំក៏បានដែរ មិត្តឯងទៅ បានចូលទៅបានជួយលើកអីៗគេ កាំភ្លើងគេប្រេកបាវប្រេកអីហើយម៉ូតូកញ្ចាស់កងអីៗទុកនៅផ្ទះហ្នឹងឯង រីឯយាយថែមបីកូនផរ៉ា គាត់ចេញពីភ្នំលាបម៉ោបានធ្លាក់ទៅនោះ ខ្ញុំបានម៉ោបានធ្លាក់ទៅកូនក្លែងហ្នឹងឯង ។

ដារ៉ា ៈ អញ្ចឹងពេលវៀតណាមចូលម៉ោពូរត់ចូលម៉ោភូមិវិញអញ្ចឹង?

សេង ៈ បាទ!ពេលវៀតណាមម៉ោ ពេលនោះខ្ញុំនៅភ្នំលាបហើយហ្នឹង ទៅភូមិកំណើតវិញឪពុកម្តាយខ្ញុំគាត់ទៅភូមិខ្ញុំវិញ ហើយខ្ញុំក៏ទៅនោះវិញក៏ជួបម៉ែឪនៅផ្ទះខ្លួនឯងនោះវិញ ពេលនោះពួកអាអ្នកដឹកនាំ ពួកនិរតីពួកអីវានាំគ្នារត់គេចទៅ ។

ដារ៉ា ៈ រត់អស់ទៅ?

សេង ៖ បាទ!រត់អស់ ។

ដារ៉ា ៖ អញ្ចឹងពេលពូរត់ម៉ោដល់ភូមិវិញ ពូមានបានសួរនាំទេថានៅក្នុងភូមិពូហ្នឹងវាជួបការ លំបាក ឬក៏យ៉ាំងម៉េចដែរ?

សេង ៖ អ្ហូ!ខ្ញុំទៅថាទឹកភ្នែកខ្លួនឯង ពុកថាមូលហេតុអីបានគាត់ស្លាប់គាត់អី គាត់ថាពុកកូនឯង ហើម គេចាស់ហើយគេឲ្យនៅចំការក៏មិនកើត អីចេះទៅរកបបរគេឲ្យតិចតួចក៏ហើម គាត់ៗស្លាប់ទៅហើយ គាត់នៅផ្ទះនៅហ្នឹងហើយកូនក៏មិនដឹងទៅណា ហើយសួរអានេះ អានោះអាណា អាណីដែលធ្លាប់ចេញទៅគាត់ថាអ្ហ៊ុយ! ស្លាប់អស់ហើយ ភាគច្រើន បើទាហានលន់ ណុល អីភាគច្រើនគេវ៉ៃចោល ហើយនឹងពួកដែលនេះណា៎! ពួកដែល គេថាសុទ្ធតែឃ្លានៗពេក ទៅលួចដំលូង លួចស្រូវអីគេទៅបាន គេចាប់បានក៏គេវ៉ៃ ចោល ។

ដារ៉ា ៖ អាហ្នឹងដឹងពីគ្រួសារ នៅភូមិ?

សេង ៖ បាទៗ! ខាងសហករណ៍គេប្រាប់ ម៉ែគាត់ប្រាប់ ប្អូនក៏ប្រាប់ ខ្ញុំក៏បាត់បង់ប្អូនប្រុសម្នាក់ ហើយនឹង ។

ដារ៉ា ៖ ប្អូនៗធ្វើអីពូ?

សេង ៖ អត់ទេគ្នាស៊ើរដែលនោះ គ្នានៅកុមារប៉ុនរកអីមិនបានហូបក៏ស្លាប់ទៅ ។

ដារ៉ា ៖ ស្លាប់នឹងដាច់ពោះអញ្ចឹង?

សេង ៖ បាទ!ស្លាប់នឹងដាច់ពោះ ។

ជាតា ៖ ក្រុមគ្រួសារពូស្លាប់អស់ប៉ុន្មាននាក់ពូសម័យហ្នឹង?

សេង ៖ ស្លាប់អស់ឪពុកមួយហើយនឹងប្អូនប្រុសមួយ អស់២នាក់ កាលហ្នឹងម្ដាយក៏ហើម ហើយគាត់ហ្នឹងសុទ្ធវែរហើម ប៉ុនដូចថារស់ៗរានមានជីវិតអីទៅ ។

ដារ៉ា ៖ ពូជំនាន់ហ្នឹងហើមដោយសារវាខ្វះជាតិអីពូ ?

សេង ៖ គិតទៅវា បើកាលពីតូចៗគេថាវាមិនបានហូបឆ្អែតបណ្ដោយ អាជាតិស្ករក៏មិនមាន អាបាយក៏មិនមាន ហើយបបរប្អូនឯងម៉ាឆ្នាំងខ្ទះត្នោត៩កំប៉ុង ១០កំប៉ុងធ្វើម៉េចមិនបានទេ វាលំបែកគ្នាម្នាក់ អាចានចង្កេះយើងហ្នឹង ភាគច្រើនគេសំបូរតែម៉ាចានចង្កេះហ្នឹងឯង ដល់យើងនិយាយ គេថាលត់ដីៗអញ្ចឹងទៅធ្វើម៉េច ហានតែប្រកែកគេថា យើងប្រកែកនឹងអង្គការ អង្គការភ្នែកមនុស្សទៅរកហើុយ ។

ប្រុញ ៖ ពូកាលហ្នឹងពូនិយាយថាដីកដីនៅត្រពាំងថ្ម កងពូកងវយ ប៉ុន្តែស្លាប់ទៅកងពូឈឺគ្នាច្រើនណាស់នៅសល់គ្នាប៉ុន្មានទេ ប៉ុន្តែចំនួនដីគេនៅចែកឲ្យយើងតាមរយៈ១០០នាក់ហ្នឹងឬក៏ម៉េចដែរពូ?

សេង ៖ អញ្ចឹងឯង ។

ប្រុញ ៖ អញ្ចឹងយើងធ្វើម៉េចទៅយើងឈឺ?

សេង ៖ អាហ្នឹងយើងចេះតែទៅៗ យើងវាស់ចែកគ្នាធំខ្លះអីទៅ ហើយបើយើងនិយាយប្រធានកងវិញស្រេចលើប្រធានកងទេ តែជាមួយប្រធានវរៈក៏បានដែរ ចុះបើកម្លាំងខ្ញុំវាឈឺអស់នៅសល់ប៉ុណ្ណោះៗបងឯងធ្វើម៉េច ឥឡូវដាក់តែម្នាក់២ម៉ែត្រៗសិនសល់ប៉ុន្មានចាំលៃចែកគ្នាទៀតទៅ ហើយខ្ញុំសុទ្ធតែមិនចេះអក្សរដែរ សុទ្ធតែអ្នកល្ងង់ធ្វើម៉េចមិនដែល ខុសធ្វើចេះត្រូវ ។

ប្រុញ ៖ មានន័យថាធ្វើច្រើនជាងគេអញ្ចឹង បើកម្លាំងយើងអត់ដល់ដីដែលគេត្រូវចែកឲ្យគ្រប់ ១០០នាក់អញ្ចឹងត្រូវធ្វើរបើនជាងគេ?

សេង ៖ យើងត្រូវធ្វើច្រើនជាងគេ ក៏ប៉ុន្តែសំខាន់បំផុតនៅលើការបើកអង្ករហ្នឹង ។

ដារ៉ា ៖ អ្ហូ!

សេង ៖ បាទ!គឺអាប្រធានវរៈហ្នឹងវាទៅយកអាភាគគេបើកអង្ករ យកពីអាអ្នកបើកអង្ករកម្លាំងអាអ្នកបើកអង្ករសួរ កម្លាំងបងឯងប៉ុន្មាន បើប្រាប់តែប៉ុនណេះៗទៅដល់មួយ ចាប់ផ្តើមថាយើងទៅមានគេសួរយើងហើយ យើងថាវរៈមួយអញ្ចឹងទៅ វាថាម៉ោអាកងឯងកម្លាំងប៉ុន្មាន ឧបមាថាយើង បើយើងកម្លាំង១០០ក៏ប៉ុន្តែឈឺអស់១០នាក់នៅសល់ ៩០នាក់ យើងថានៅទាំង១០០ទៅ គឺវាដាល់ឲ្យទាំង១០០ វាទៅចេះដែរ ។

ដារ៉ា ៖ អញ្ចឹងពេលយើងប្រាប់គេថានៅសល់១០០ គឺអាពេលបើករបបម៉ោក៏១០០ដែរ?

សេង ៖ ម៉ា១០០ ហើយវាស់ដីឲ្យ១០០ដែរ ។

ដារ៉ា ៖ វាស់ដី១០០នាក់ដែរ?

សេង ៖ បាទ!

ដារ៉ា ៖ ទោះបីជាកម្លាំងយើងនៅសល់៨០ឬ៩០ក៏ដោយ?

សេង ៖ បាទ!ក៏ដោយ គេអត់ម៉ោតាមដានម៉ោសួរអីជាក់ស្តែងទេ?

ដារ៉ា ៖ គេមិនសួរទេ ។

ជាតា ៖ ចុះពូមានដែលប្រាប់គេថាកម្លាំងខ្ញុំនៅសល់តែ៨០ទេ ឥឡូវឈឺអស់២០នាក់អញ្ចឹង ទៅ?

សេង ៈ ទេមុនដំបូងគាត់វាស់១០០ៗ ដល់វាស់១០០ៗទៅក៏បានអង្ករបរបូណ៍ហូរហៀរអង្ករសល់ទៀតនោះ ដាំទុកសល់កន្ទះៗបាវ ទុកចុះមាំថ្ងៃសន្សំតិចៗ ខ្ញុំប្រាប់ថាឯងដាំមើល បើថាសល់ដាក់ឲ្យច្រើនតិច បើថាវាមើលទៅបាយសល់ច្រើនយើងទុក ដល់ម៉ោវាស់ដី ១០០ខ្ញុំថាអត់កើតទេវើយ! ហត់ខ្លួនឯងស្រួលមិនស្រួល ដូច្នេះយោបល់នេះខ្ញុំសួរបងប្អូនម៉ោពីភ្នំពេញគេអ្នកចេះច្រើន យើងល្ងង់យើងមិនធ្មើចេះទេ ប៉ុនយើងសួរ មាំធ្វើម៉េចបានត្រូវ? ព្រោះអង្ករការគេនិយាយថាភាគតិចគោរពភាគច្រើនបុគ្គលគោរពសមូហភាព ហៅម៉ោសុទ្ធតែពួកអ្នកទុកចិត្ត ដូចអាម៉ាប់អីហ្នឹងវាថាវាក្មួយអ៊ិន គាំ បង្កើត។

ដារ៉ា ៈ អ្ហូ!

សេង ៈ បាទ!អាម៉ាប់យើងហ្នឹង! វាសុំខ្ញុំទៅៗសុំខ្ញុំដល់លើកនេះវាសុំរត់ត្រង់ ដល់ទៅដល់នេះគេបាញ់ត្រូវ រត់ម៉ោវិញ តែមិនដឹងឈ្មោះវាពិតប្រាកដឈ្មោះអីទេ ប៉ុនវាប្រាប់ថាវាទៅរកៗមារវានៅថៃ។

ដារ៉ា ៈ អ្ហូ!មារហ្នឹងឈ្មោះអី?

សេង ៈ អ៊ិន គាំ ហៅអ៊ិន គាំ ក៏ប៉ុន្តែទៅដល់ វាទៅ២នាក់ អាមួយស្លាប់ អាមួយវានៅឈ្លូលគោកលន់អានៅសហករណ៍វា ប៉ុនគេបំបែកចូលចល័តតំបន់អាហ្នឹងវាត្រូវ ត្រូវឆាកនេះដំបៅ វាម៉ោរកខ្ញុំឃើញវិញ។

ដារ៉ា ៈ ម៉ោរកនៅណា?

សេង ៈ ម៉ោរក កាលហ្នឹងខ្ញុំនៅលើកទំនប់កំបោរស្រែះនេះ វារត់តាំងពីកាលហ្នឹងឯង ដល់វាម៉ោវិញវាប្រាប់រឿងហេតុទៅ។

ដារ៉ា ៈ ឈ្មោះអី?

សេង ៈ ឈ្មោះវាមិនមែនឈ្មោះអាម៉ាប់ទេ ប៉ុនខ្ញុំហៅវាតែអាម៉ាប់។

ដារ៉ា ៈ អ្ហូ!ឈ្មោះម៉ាប់ហ្នឹងដែលត្រូវគ្រាប់ហ្នឹង?

សេង ៈ បាទ!ដែលត្រូវគ្រាប់។

ដារ៉ា ៈ អត់ចាំឈ្មោះគាត់ទេ?

សេង ៈ អត់ចាំទេ មិនដឹងជាឈ្មោះវាពិតប្រាកដអីទេ ប៉ុនខ្ញុំឃើញវាធំត្រឡោកខ្ញុំហៅវាតែអាម៉ាប់ៗទៅជាប់អាម៉ាប់ទៅមិនដឹងជាឈ្មោះវាហៅអី។

ដារ៉ា ៈ តែក្រោយម៉ោនៅរស់ទេ ឈ្មោះហ្នឹង?

សេង ៖ បែកគ្នា ចាប់ពីហ្នឹងម៉ោបែកទៅសហករណ៍រៀងខ្លួនចូលឆ្នាំហ្នឹង គេបំបែកឲ្យទៅសហករណ៍រៀងខ្លួនចាំថ្ងៃទីប៉ុននេះៗចាំម៉ោជួបគ្នាវិញ ដល់យើងទៅសហករណ៍ចូលឆ្នាំកាលហ្នឹងចូលឆ្នាំគេឲ្យម៉ោចូលឆ្នាំតាមភូមិកាលហ្នឹង៣ថ្ងៃ ។

ដារ៉ា ៖ អ្ហូ!បាទ?

សេង ៖ បាទ! ដល់ម៉ោ៣ថ្ងៃទៅ ខ្លះវាមាននៅណាបាន ចុះយើងដល់ចូលសហករណ៍គេឲ្យរបបសហករណ៍ស៊ីមិនឆ្អែតក៏ទៅបណ្តើរៗទៅវិញ យើងនៅនោះ យើងធ្វើការនឿយមែនក៏ប៉ុន្តែបានហូបឆ្អែត នៅសហករណ៍ធ្វើការនឿយក៏ប៉ុន្តែវាហូបអត់ឆ្អែត ។

ប្រុញ ៖ ពូនិយាយពេលហ្នឹងថាវែកទឹកវែកអីម៉ោធ្វើស្ពាន អញ្ចឹងចុះពេលដែលវែកហូប វែកទឹកផ្ទួតអីម៉េចដែលពូ?

សេង ៖ អាហ្នឹងគឺទឹកគេបើក មានរបបគេបើកឲ្យ តែបើកវាមិនគ្រប់ ក៏ប៉ុន្តែបើសិនជាយើងវាមានអីទេ មានតែយើងកាប់យើងជីកខ្លួនយើង ។

ដារ៉ា ៖ ជីកដី?

សេង ៖ បាទ!ជីកអណ្តូងខ្លួនយើង កាលហ្នឹងទឹកយើងជីកជម្រៅណាណីហើយ ម៉ាម៉ែត្រជាងហើយវាមិនចង់ចេញទៀត ដល់ជីកៗទៅជួនកាលប៉ះអាណាដែលចេញម៉ាយប់អីបានម៉ាធុង ២ធុងអីទៅណា! អញ្ចឹងជួនណាដែលវាមិនចេញទៅក៏បាន២-៣ដ្ឋលទៅចេះតែជីកទៅតស៊ូធ្វើម៉េច ជីកអាត្រង់ពោះប្រឡាយយើង ។

ប្រុញ ៖ ជីកអញ្ចឹងចុះទឹកផ្ទួតវិញពូ?

សេង ៖ អ្ហូ!ទឹកផ្ទួតពិបាកបន្តិចហើយ ។

ប្រុញ ៖ អត់មានទឹកផ្ទួតទេ?

សេង ៖ មានខ្លះ អាខ្លះទឹកក្របីទឹកគោ ទឹកអីក៏ប៉ុន្តែរយៈពេលវាខ្លី វាមិនមានយូរ រយៈពេល ២-៣ខែអាខែប្រាំងដែលវាមិនភ្លៀងវាមានរយៈពេលខ្លីដែរ ។

ប្រុញ ៖ ចុះជំនាន់ហ្នឹងមានឈឺស្លាប់ច្រើនទេពូ ជំនាន់ជីកត្រពាំងថ្មហ្នឹង?

សេង ៖ បើឈឺស្លាប់ដូចតិច ។

ប្រុញ ៖ ស្លាប់តិចដែរ?

សេង ៖ បាទៗ! បើស្លាប់ច្រើន ស្លាប់ដោយសារគេវៃចោល ។

ដារ៉ា ៖ គេយកទៅសម្លាប់ហ្នង?

សេង : បាទ! គេយកទៅសម្លាប់ ខ្ញុំអាមួយហ្នឹងនៅកងខ្ញុំវាក្មេងយ៉ូស ខ្ញុំហៅគាត់តែតាញ៉ូបៗ មិនដឹងឈ្មោះគាត់ស្អីតាហ្នឹងពេលដែលគាត់ គេយកគាត់ទៅនេះទៅ ចុះគាត់ដាំជាមួយខ្ញុំរាល់ថ្ងៃ ដល់បាត់គាត់តែ២ថ្ងៃអញ្ចឹងសួរ អេ៎! បាត់តាវែនតាទៅណាតាញ៉ូបទៅណា? តាហ្នឹងគ្រុនៗបានបន្តិចបាន អាមួយនៅចុងភៅនោះប្រាប់អាអ្នកដាំបាយ ហ៊ឺ! តាវែនតាងាប់ទៅហើយ ។ អ៊ីយ៉ា! ឃើញងាប់បណ្តោយ ហើយតាវែនតាហ្នឹងពួកខ្ញុំខស្សព្រាហ៍លេងគាត់មិនដឹងបាបកម្មម៉េចសុំគាត់កុំឲ្យមាន គាត់ពាក់វែនតាដាច់ដៃម្ខាងគាត់លូកដៃចង១ទៅ តែដោះវែនតាហ្នឹងទៅមើលអត់ឃើញទេ រាវអីមិនឃើញ បងសេង កុំធ្វើបាបខ្ញុំបងសេងណាវែនតាខ្ញុំ អ៊ូ! វែនតាអើយកំពាត អន្តួយដុំប៉ុកៗ ដល់យកទៅកប់ៗទៅថាអ៊ូ! ធ្វើម៉េចអានេះណាដកកម្លាំង៣នាក់ទៅកប់ កប់ចំណាំផងណាថាបាទយកទៅកប់នៅក្រោមស្ពានទី៣មានដើម មានដំបូកធំមួយមានដើមទ្រេតទៅចេះ រាងទ្រេតទៅត្បូងចេះកប់នៅហ្នឹងដែរខ្ញុំបានទៅមើល កប់រួចបានអាមួយថាខ្ញុំបានមើលមុខគាត់ដែរ កប់រួចបានអាមួយថា ខ្ញុំបានមើលមុខគាត់ទៅតាមហ្នឹងប៉ុន្មានខែ ហើយធាតុក៏មានរូបថតក៏មាន រូបថតម៉ែឪគាត់ ប្អូនបងប្អូនទាំងអស់ ហើយណែ៎! ឆ្អឹងថាឆ្អឹងបងប្អូនគាត់ដាក់ម៉ោជាមួយដែរ ហើយនឹងមាស មាសខ្ញុំមិនបានឃើញទេពួកនោះហ្នឹងវាថាថ្ងៃមុនឲ្យខ្ញុំមើលខ្ញុំមើលឃើញមាស២-៣ខែ ។

ដារ៉ា : គាត់លាក់តាមណា?

សេង : ប៉ុនគេឆែកគេអីខ្លះដែរ ប៉ុនដល់យើងមិនត្រូវការដូរត្រូវការអី ដូនណាគេទាមាសទៅបងប្អូនណាមានមាសមានអីគឺយកមកជូនអង្គការទាំងអស់ តែអង្គការឆែកឃើញ គេសម្លាប់ចោល ប៉ុនអ្នកណាឲ្យក៏ឲ្យអ្នកណាមិនឲ្យក៏ឲ្យទៅ ហូបបាយឆ្អែតហើយយើងមិនត្រូវការដោះដូរអី ចំណាយមាសធ្វើអី ដល់អញ្ចឹងទៅខ្ញុំទៅមើលកន្លែងមើលអីចំណាំបានក៏ប៉ុន្តែដល់ទៅរកមាសរកអីទៅរកក៏មិនឃើញ កាលហ្នឹងគាត់ឆ្អឹងពុកក៏ដាក់ម៉ោជាមួយដែរអាណិតគាត់ណាស់ ។

ដារ៉ា : ពូខ្ញុំដូចជាបានពត៌មានច្រើនដែរហើយ ខ្ញុំសុំបញ្ចប់ការសម្ភាសន៍តែត្រឹមហ្នឹង ហើយប្រសិនជាខ្ញុំមានសំនួរអីផ្សេងទៀត ខ្ញុំអាចទូរស័ព្ទមកសួរពូបន្តទៀតបានទេពូ?

សេង : បានៗ ។

ដារ៉ា : អត់អីទេពូ?

សេង : បាទៗ! ។

ដារ៉ា : អញ្ចឹងពួកខ្ញុំសូមអរគុណពូច្រើនដែលបានផ្តល់បទសម្ភាសន៍នេះពូ?

សេង : បាទៗ ។

«ចប់»